**សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងសំរាម និងកាកសំណល់រឹងរាវ នៅក្នុងរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ឆោម ស្រីវីន**

**យ៉ា សុខា**

សាស្ត្រាចារ្យណែនាំ

សាស្ត្រាចារ្យ **ឃូ តូនី**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **នោម ស្រីវីន** និង **យ៉ា សុខា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែករដ្ឋបាលសាធារណៈ ក្រុម $P_4A_1$ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០ ~ ២០២១។

សូមថ្លែងអំណរគុណនិងសម្ដែងការថ្លែងអំណរអរគុណចំពោះ៖

- លោកឪពុក អ្នកម្ដាយ ទាំងពីរដែលលោកជាអ្នកមានគុណយ៉ាងធំធេងក្រៃលែង ចំពោះកូនដែលមានតម្លៃពុំអាចកាត់ថ្លៃបាន ព្រោះថាលោកទាំងពីរជាអ្នកដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនៗតាំងតែពីថ្ងៃដែលកូនបានចាប់កំណើតនៅក្នុងផ្ទៃ រហូតដល់ថ្ងៃដែលកូនកើត ហើយនៅពេលដែលកូនធំដឹងក្ដីបន្តិចឡើង លោកទាំងពីរបានទូន្មាន ណែនាំ អប់រំ ប្រៀនប្រដៅ ដាស់តឿនកូនឲ្យក្លាយជាកូនល្អ ប្រព្រឹត្តតែអំពើល្អ សេពគប់មិត្តល្អជាដើម លើសពីនេះទៅទៀតលោកទាំងពីបានខិតខំធ្វើការទាំងថ្ងៃក្ដៅ ថ្ងៃរងាត្រជាក់សព្វបែបយ៉ាងដើម្បីបានថវិកាមកទំនុកបម្រុងការសិក្សារៀនសូត្ររបស់កូន ព្រមទាំងផ្ដល់ការស្រលាញ់ ការថ្នាក់ថ្នម ភាពកក់ក្ដៅ និងការរស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរដល់កូនៗទាំងអស់គ្នាទាំងនេះគឺជាមហាគុណដ៏ធំធេងដែលកូនពុំអាចបំភ្លេចបានឡើយនៅក្នុងឆាកជីវិតរបស់កូន។
- ឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យគ្រប់រូបនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ដោយមានទំនួលខុសត្រូវយ៉ាងខ្ពស់ចំពោះការសិក្សារបស់និស្សិតទាំងអស់ ដោយលោកពុំគិតពីបញ្ហាលំបាកនឿយហត់អ្វីឡើយ។ លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យគ្រប់រូបក៏តែងតែខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវ រិះរកបកគំហើញថ្មីៗ បន្ថែមដើម្បីផ្ទេរនូវពុទ្ធិ និងបទពិសោធន៍ល្អដល់សិស្សនិស្សិតគ្រប់គ្នាផងដែរ។
- ជាពិសេសខ្ញុំថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យ **យូ តុនី** ដែលជាសាស្ត្រាចារ្យណែនាំរបស់នាងខ្ញុំ ដែលតែងតែផ្ដល់នូវគ្រឹះ ការអនុវត្តក្នុងការសិក្សាស្វែងយល់ពីរបៀបក្នុងធ្វើសារណារបស់នាងខ្ញុំ សាស្ត្រាចារ្យថែមទាំងព្យាយាមពន្យល់ណែនាំ និងប្រាប់នូវបទពិសោធន៍ល្អៗ ព្រមទាំងវិធីសាស្ត្រផ្សេងៗដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវផងដែរ។
- ជាចុងបញ្ចប់នាងខ្ញុំសូមជូនពរឲ្យលោកឪពុក និងអ្នកម្ដាយ លោកយាយ លោកតា លោកពូ អ្នកមីង និងអ៊ំៗ ឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យ មិត្តិនិស្សិត និងបុគ្គលដែលបម្រើការងារនៅ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ មានតែសុខភាពល្អ សម្រេចបានជោគជ័យគ្រប់ភារកិច្ច។

# **អារម្ភកថា**

នាងខ្ញុំទាំងពីរនាក់ពិតជាមានអារម្មណ៍សប្បាយរីករាយណាស់ ដែលបានសម្រេចចិត្តជ្រើសរើសចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាសាកលវិទ្យាល័យមួយដែលបានផ្តល់នូវជម្រកកក់ក្តៅដល់នាងខ្ញុំ **យ៉ា សុខា** និង **ឆោម ស្រីវីន** រយៈពេលបួនឆ្នាំក្នុងការសិក្សាបរិញ្ញាបត្ររដ្ឋបាលសាធារណៈ ក្រៅពីការណែនាំ ទូន្មាន អប់រំ ប្រៀនប្រដៅ ពីសំណាក់លោកឪពុក អ្នកម្តាយ ដែលជាគ្រូដំបូងរបស់យើងខ្ញុំឬ/និងជាគ្រូទីមួយ ដែលបានផ្តល់នូវការដាស់តឿន បង្ហាត់បង្រៀន បង្ហាញផ្លូវល្អហើយយើងខ្ញុំពិតជាមានសំណាងល្អណាស់ដែលបានចូលរៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងមានសំណាងណាស់ដែលបានមកជួបសាស្ត្រាចារ្យដែលមានចំណេះដឹង បទពិសោធន៍ ក្រមសីលធម៌ខ្ពស់ក្នុងការបង្ហាត់បង្រៀន ការផ្ទេរនូវពុទ្ធិ ចែករំលែងនូវចំណេះដឹងនិងការដាស់តឿនប្រកបដោយវិជ្ជាជីវៈហើយពុំដែលគិតពីការលំបាក ភាពនឿយហត់អ្វីឡើយ។

នៅក្នុងផ្នែកមួយនៃការសិក្សាបរិញ្ញាបត្ររដ្ឋបាលសាធារណៈរយៈពេលបួនឆ្នាំ យើងខ្ញុំបានចាប់អារម្មណ៍លើប្រធានបទមួយដែលទាក់ទងនឹង ការគ្រប់គ្រងសំរាមនិងកាកសំណល់រឹងនិងរាវនៅក្នុងរាជធានីភ្នំពេញ ដែលយើងខ្ញុំយល់ថា នៅក្នុងរាជធានីភ្នំពេញសម័យបច្ចុប្បន្នគឺមានកំណើននៃចំនួនប្រជាជនរស់នៅច្រើនដែលជាហេតុនាំឲ្យមានការកើនឡើងនៃសំរាមនិង ការបំពុលផ្សេងៗដែលបណ្តាលមកពីការគ្រប់គ្រងសំរាមនូវមិនទាន់បានល្អ ហេតុនេះហើយបានជាយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ ″ការគ្រប់គ្រងសំរាមនិងកាកសំណល់រឹងនិងរាវក្នុង រាជធានីភ្នំពេញ″ មកធ្វើការសិក្សាស្រាវជ្រាវដើម្បីបានជាគន្លឹះ ឯកសារនិងចំណេះដឹងបន្ថែមដល់និស្សិតជំនាន់ក្រោយៗបន្តទៀត។

បើទោះបីជាខ្លឹមសារទាំងស្រុងនៅក្នុងសៀវភៅសារណា ឬរបាយការណ៍កម្មសិក្សានេះមានការពិនិត្យយ៉ាងយកចិត្តទុកដាក់យ៉ាងណាក្តី យើងខ្ញុំគិតថាវានូវតែមានចំណុចមួយចំនួន និងមានន័យខុសឆ្គង ឬ/និងអាចថាខុសនូវអក្ខរាវិរុទ្ធខ្លះ ដោយអចេតនា ឬការភ្លាំងភ្លេចខ្លះ ជាក់ជាមិនខានឡើយ តែទោះបីជាយ៉ាងណា យើងខ្ញុំទាំងពីរនាក់សូមទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តអ្នកអាន មិត្តនិស្សិតទាំងអស់គ្នា ដើម្បីឲ្យការសិក្សាស្រាវជ្រាវក្រោយទៀតកាន់តែមានភាពសុក្រឹត្យ និងល្អប្រសើរហើយទទួលបានផលប្រយោជន៍ច្រើនដល់មិត្តអ្នកអាននិងមិត្តនិស្សិតជំនាន់ក្រោយៗទៀត។

នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំ ឯកសារដែលនាងខ្ញុំបានរៀបចំឡើងនេះ និងផ្តល់នូវចំណេះដឹងបន្ថែមដល់និស្សិតក្នុងការសិក្សានិងស្រាវជ្រាវ។ ទោះបីជាខ្ញុំខំប្រឹងប្រែងយ៉ាងណាក៏នូវតែមានកំហុសកើតមានឡើងដោយអចេតនាកើតមាន នាងខ្ញុំសូមរង់ចាំនូវការរិះគន់ ទាំងឡាយ ដើម្បីស្ថាបនាឲ្យកាន់តែមានភាពសុក្រិតនិង ល្អជាងនេះបន្ថែមទៀត។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........................................................................................................................ ១

**ជំពូកទី១**

**ការគ្រប់គ្រងសំរាម**

១.១. និយមន័យ និងប្រភេទ ........................................................................................................ ២

១.២.ការចាត់ថែងសំរាមទៅតាមប្រភេទ ........................................................................................ ៣

១.២.១.ការទាញយកប្រយោជន៍ពីសំរាម ............................................................................ ៥

១.២.២.ការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ...................................................................... ៨

១.៣.មូលហេតុនៃកំណើនបរិមាណសំរាម វិធីសាស្ត្រនៃការគ្រប់គ្រងសំរាមនៅកម្ពុជា ........................... ១០

១.៣.១.វិធីសាស្ត្រដែលគ្រប់គ្រងសំរាមប្រើប្រាស់ដោយប្រជាពលរដ្ឋ ........................................ ១១

១.៣.២.វិធីសាស្ត្រគ្រប់គ្រងសំរាមដែលប្រើប្រាស់ដោយស្ថាប័នរដ្ឋ ឬអាជ្ញាធរមូលដ្ឋាន ............... ១១

១.៤.ផលប៉ះពាល់នៃការគ្រប់គ្រងសំរាម ...................................................................................... ១៣

១.៤.១.ការចោលសំរាមនៅទីសាធារណៈ ............................................................................ ១៣

១.៤.២.ផលប៉ះពាល់នៃការដុតសំរាម ................................................................................. ១៤

១.៤.៣.ផលប៉ះពាល់នៃទីលានចាក់សំរាម ............................................................................ ១៥

**ជំពូកទី២**

**ការគ្រប់គ្រងកាកសំណល់រឹង**

២.១.ប្រភេទនិង បញ្ហានៃកាកសំណល់រឹង ...................................................................................... ១៦

២.១.១.កាកសំណល់សរីរាង្គ កាកសំណល់ប្លាស្ទិក ................................................................ ១៧

២.១.២.កាកសំណល់ក្រដាស កាកសំណល់វាយនភណ្ឌ ........................................................... ១៨

២.១.៣.កាកសំណល់កែវ កាកសំណល់លោហៈធាតុ.................................................................. ១៩

២.១.៤.កាកសំណល់អេឡិចត្រូនិច ...................................................................................... ១៩

២.២.ការគ្រប់គ្រងកាកសំណល់រឹង ................................................................................................. ២០

២.២.១.នៅក្នុងរាជធានីភ្នំពេញ និងនៅតំបន់ជាយក្រុង ........................................................... ២០

២.២.២.បញ្ហាប្រឈមនិងដំណោះស្រាយ ............................................................................... ២០

# ជំពូកទី៣
# ការគ្រប់គ្រងសំណល់រាវ


៣.១.ការគ្រប់គ្រងប្រព័ន្ធបង្ហូរទឹកកខ្វក់ ........................................ ២៨

៣.១.១.ការគ្រប់គ្រងប្រព័ន្ធលូ ........................................ ២៨

៣.១.២.ការគ្រប់គ្រងប្រព័ន្ធទឹកលូ ........................................ ២៩

៣.២.ការបញ្ចេញកាកសំណល់រាវដោយមិនបានធ្វើប្រព្រឹត្តកម្មកម្ទាត់ ........................................ ២៩

៣.៣.ការបំពុលនៃកាកសំណល់រាវ ........................................ ៣០

៣.៣.១.ការបំពុលបរិស្ថាន ........................................ ៣០

៣.៣.២.ការបំពុលទឹក ........................................ ៣២

៣.៣.៣.ការបំពុលដី ........................................ ៣៣

**សេចក្តីសន្និដ្ឋាន** ........................................ ៣៤

**អនុសាសន៍** ........................................ ៣៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បច្ចុប្បន្ន នៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសនៅទីក្រុងភ្នំពេញ ការអភិវឌ្ឍន៍ និងការរីកចម្រើនផ្នែកសេដ្ឋកិច្ចព្រមទាំងកំណើនប្រជាពលរដ្ឋពីជនបទចូលមកនៅក្នុងទីក្រុង ដើម្បីស្វែងរកការងារធ្វើដោះស្រាយជីវភាព ការកើនឡើងចំនួនប្រជាពលរដ្ឋដែលរស់នៅទីក្រុងនិងទីប្រជុំជន ក៏ដោយសារការរីកចម្រើនផ្នែកឧស្សាហកម្ម។ ហេតុនេះហើយដោយសារតែកំណើនប្រជាជនដែលរស់នៅក្នុងទីក្រុងមានការកើនឡើងបែបនេះ វាក៏ជាកត្តាមួយដ៏សំខាន់ដែលរួមចំណែកធ្វើឲ្យមានការកើនឡើងនៅសំរាមក្នុងរាជធានីភ្នំពេញដែលមានចំនួន ១០,០០០តោនជារៀងរាល់ថ្ងៃ ដូច្នេះហើយការគ្រប់គ្រងកាកសំណល់នៅបន្តជាបញ្ហាប្រឈមសម្រាប់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាទីក្រុងផ្សេងៗទៀតក្នុងប្រទេសកម្ពុជា សេដ្ឋកិច្ច របស់យើងមានការវិវត្តន៏វិលជុំនៃការបង្កើត ការប្រើប្រាស់ និងការបោះចោល កំពុងតែបង្កើតកាកសំណល់កាន់តែច្រើនឡើងៗជារៀងរាល់ឆ្នាំ។ សហគមន៍ក្រីក្រពុំទាន់ទទួលបាន សេវាគ្រប់គ្រងកាកសំណល់នៅឡើយទេ ដូច្នេះពួកគាត់ត្រូវការជំនួយបន្ថែមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗទៀត។ ប្រហែល៣៥.៧ ភាគរយ នៃសហគមន៍ក្រីក្រ ២៧៧ ក្នុងរាជធានីភ្នំពេញ នៅតែមិនទាន់ទទួលបានសេវាគ្រប់គ្រងកាកសំណល់ បានគ្រប់គ្រាន់នោះទេ។ វានាំឲ្យមានបញ្ហាជាច្រើនដែលរួមបញ្ចូលទាំងសុខភាពសាធារណៈ ការគ្រប់គ្រងធនធាន និងបណ្តាញផ្លូវទឹកក្នុងតំបន់ផងដែរ។ រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗទៀតបានដឹងពីបញ្ហានេះ ប៉ុន្តែមិនទាន់អាចធ្វើកិច្ចការនេះបានច្រើននៅឡើយនោះទេ។ ហេតុនេះហើយបានជានៅពេលបច្ចុប្បន្នបញ្ហាសំរាមនៅក្នុងរាជធានីភ្នំពេញនៅតែជាបញ្ហាចោទដែលរាជរដ្ឋាភិបាលក៏ដូចជាសាលារាជធានីភ្នំពេញត្រូវការយកចិត្តទុកដាក់លើបញ្ហានេះនិងរកដំណោះស្រាយ ដោយក្នុងនោះផងដែរសាលារាជធានីភ្នំពេញបានធ្វើការសហការជាមួយក្រុមហ៊ុនឯកជនក្នុងការដោះស្រាយបញ្ហាសំរាមនៅក្នុងរាជធានីភ្នំពេញ ក្រៅពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលនិងសាលារាជធានីភ្នំពេញទៅលើបញ្ហាសំរាមហើយក្នុងនាមយើងជាប្រជាពលរដ្ឋគួរយល់ដឹងអំពីការគ្រប់គ្រងកាកសំណល់និងការបោះចោលកាកសំណល់នេះឲ្យបានត្រឹមត្រូវនិងចូលរួមថែរក្សាបរិស្ថាននៅក្នុងទីក្រុងយើងឲ្យមានសោភណ្ឌភាពស្រស់បំព្រងផងដែរ និងធ្វើឲ្យការរស់នៅរបស់យើងប្រចាំថ្ងៃមានផាកសុខភាពល្អ និងបង្កើតភាពស្រស់ស្អាតរបស់ទីក្រុងយើងផងដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍទីក្រុងក៏ដូចជាអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិក៏ដូចជាទេសចរណ៍អន្តរជាតិឲ្យចូលមកលេងក្នុងទីក្រុងរបស់យើងបានទៀតផងនៅពេលដែលប្រជាពលរដ្ឋរបស់យើងយល់ដឹងនិងគ្រប់គ្រងកាកសំណល់បានល្អ ទីក្រុងយើងស្អាតគឺផ្តើមចេញពីយើងទាំងអស់គ្នាដែលជាប្រជាពលរដ្ឋក្នុងការចូលរួមថែរក្សាបរិស្ថានបានល្អ។

# ជំពូកទី១
# ការគ្រប់គ្រងសំរាម

## ១.១.និយមន័យនិងប្រភេទ

*សំរាម* គឺជា សំណល់ដែលគេបោះចោល ឬចាក់ចោលនៅទីកន្លែងផ្សេងៗគ្នា ដោយសារតែគេលែងត្រូវការវាទៀត។ សំរាមគឺជា កាកសំណល់គ្រប់ប្រភេទដែលសល់ពីបម្រើបម្រាស់ ប្រចាំថ្ងៃហើយត្រូវ បញ្ចេញចោលតាមសកម្មភាពសព្វបែបយ៉ាងពីប្រភពផ្សេងៗ។



សំរាមអាចចែកចេញជា ៤ប្រភេទគឺៈ សំណល់លំនៅស្ថាន សំណល់ទីផ្សារ សំណល់ឧស្សាហកម្ម និង សំណល់មន្ទីរពេទ្យ។

1. សំណល់លំនៅស្ថាន : គឺជាផ្នែកមួយនៃសំនល់រឹង ដែលមិនមានសារធាតុពុល ឬសារធាតុគ្រោះថ្នាក់ ហើយត្រូវបានបោះចោលពីផ្ទះឯកជន អគារសាធារណៈ រោងចក្រ ទីផ្សារសណ្ឋាគារ អគារពាណិជ្ជកម្ម ភោនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត។
2. សំណល់ទីផ្សារ : សំណល់នេះភាគច្រើនជាប្រភេទសំណល់សរីរាង្គដែលងាយនឹងបំបែកធាតុដោយពពួកមីក្រូសារពាង្គកាយ ហើយជាប្រភេទអាចយកទៅធ្វើជាជីកំប៉ុសបាន។
3. សំណល់ឧស្សាហកម្ម : សំណល់រឹងដែលបង្កើតចេញពីរោងចក្រ កំទេចក្រណាត់ កាកសំណល់ផ្ទះបាយ ប្លាស្ទិក ក្រដាស សំបកបារ កំទេចថ្មស្អុយ កំទេចថ្នាំជក់ អំបែងដប ដែក ស្បែក កំទេចឈើ សំណល់កៅស៊ូក្រៃប សំណល់ការ សំណល់ស័ង្កសី សំណល់ភក់ដែលចេញពីការបោកគក់។
4. សំណល់មន្ទីរពេទ្យ : សំណល់ទាំងនោះមានដូចជា សារាំង ម្ជុល បង់រុំរបួស សំឡី សំណល់ថ្នាំពេទ្យ និងបំណែករាងកាយ....។ ចំពោះការទុកដាក់និងការបោះចោល គឺពុំទាន់អនុវត្តបានល្អនៅឡើយដោយសារ

មន្ទីរពេទ្យភាគច្រើនមិនមានឡសម្រាប់ដុត ដូច្នេះហើយគេ (មន្ទីរពេទ្យ) បានយកសំណល់ប្រកបដោយគ្រោះថ្នាក់ទាំងនោះប្រគល់ទៅឲ្យក្រុមហ៊ុនប្រមូលសំរាមជាអ្នកដឹងយកទៅចាក់ចោល។

## ១.២.ការចាត់ចែងសំរាមទៅតាមប្រភេទ

នៅពេលដែលកាកសំណល់បានចាក់ជាគំនរ ឬរាយប៉ាយក្នុងសហគមន៍របស់យើង វាមានសភាពអាក្រក់មើល មានក្លិនមិនល្អ និងមិនល្អសម្រាប់សុខភាព។ នៅពេលមិនបែងចែកប្រភេទកាកសំណល់ និងបរិមាណកាកសំណល់ និងបញ្ហាដែលកើតឡើង ដោយកាកសំណល់ គឺមានទំហំធំធេងជាងដែលការរៀបចំកាកសំណល់ទៅទៀត។ នៅពេលកាកសំណល់បង្កគ្រោះថ្នាក់ ដូចជាថ្មពិលចាស់ៗ និងកាកសំណល់នៃការថែទាំសុខភាព ត្រូវបានដាក់រួមគ្នាជាមួយកាកសំណល់ដទៃដូចជាក្រដាស និងសំណល់អាហារ នោះល្បាយកាកសំណល់នេះកាន់តែមានការពិបាកនិង មានគ្រោះថ្នាក់ក្នុងការដោះស្រាយ។ នៅពេលមិនបានបោះចោលត្រឹមត្រូវ កាកសំណល់បណ្តាលឲ្យមានបញ្ហាដល់សុខភាពជាច្រើន។



ការដាក់កាកសំណល់មិនឲ្យឡូកឡំគ្នា ធ្វើឲ្យមានភាពងាយស្រួលក្នុងការប្រើប្រាស់ឡើងវិញ កែច្នៃ ឬបោះចោលសម្ភារៈនោះ នឹងជួយបង្ការបញ្ហាសុខភាពដែលបណ្តាលមកពីការដាក់សំណល់រួមគ្នា។ ការដាក់កាកសំណល់ដាច់ដោយឡែកពីគ្នាគឺជាជំហានទី១ ក្នុងការគ្រប់គ្រងកាកសំណល់យ៉ាងល្អប្រសើរ ទោះបីវាអាចដោះស្រាយបញ្ហាបានលុះត្រាតែមានវិធីល្អក្នុងការរៀបចំកាកសំណល់បន្ទាប់ពីដាក់ដោយឡែកហើយ។ ការបែងចែកប្រភេទកាកសំណល់ គឺជាផ្នែកមួយនៃប្រព័ន្ធ ដែលរយមមានការប្រើប្រាស់ឡើងវិញ ការធ្វើជីកំប៉ុស ការប្រមូលកាកសំណល់ជាប្រចាំ និងការចោលកាកសំណល់ប្រកបដោយសុវត្ថិភាព។

ផ្នែកដ៏ធំបំផុតនៃកាកសំណល់ដែលបានបង្កើតនៅក្នុងទីក្រុង និងជនបទ គឺជាកាកសំណល់សារធាតុសរីរាង្គ ឬកាកសំណល់សើម (កាកសំណល់អាហារ និងកាកសំណល់នៅសួនដំណាំ ដូចជារុក្ខជាតិនិងស្លឹកឈើងាប់)។ កាកសំណល់សារធាតុសរីរាង្គត្រូវបានបំបែកដោយពន្លឺថ្ងៃនិងទឹក ឬត្រូវបានស៊ីដោយវត្ថុមានជីវិត (ដង្កូវ សត្វល្អិត និងបាក់តេរី) រួចក្លាយទៅជាជីកំប៉ុស។ ជាធម្មតាមានក្រដាស កញ្ចក់ លោហៈ និងប្លាស្ទិក ជាច្រើននៅក្នុងកាកសំណល់។ ផ្នែកដ៏ធំនៃកាកសំណល់នេះត្រូវបានបោះចោលជាកញ្ចប់។ កាកសំណល់តាមផ្ទះអាចមានរួមបញ្ចូលសារធាតុពុល ដូចជាថ្នាំលាប ថ្មពិល ខោទឹកនោមកុមារធ្វើពីប្លាស្ទិក ប្រេងម៉ាស៊ីន ថ្នាំសម្លាប់សត្វល្អិតចាស់ៗ និងប្រដាប់ដាក់ផលិតផលសម្អាត។

គេបែងចែកកាកសំណល់ជា៣ប្រភេទគឺ៖

- <u>កាកសំណល់សើមក្លាយទៅជាជីកំប៉ុស</u>

ដោយសារសារធាតុសរីរាង្គជាទូទៅគឺជាផ្នែកមួយដ៏ច្រើនបំផុត នៃកាកសំណល់ភាគច្រើនដូច្នេះការបែងចែក និងធ្វើជីកំប៉ុសនូវកាកសំណល់អាហារ ជួយកាត់បន្ថយកាកសំណល់បានយ៉ាងច្រើន។ ការដាក់ជីកំប៉ុសទៅឲ្យដី គឺជាវិធីមួយក្នុងការ ផ្តល់សារធាតុចិញ្ចឹមរបស់ដំណាំ ឲ្យត្រឡប់ទៅផែនដីវិញ។ វិធីធ្វើជីកំប៉ុសដែលល្អបំផុតគឺអាស្រ័យលើទីធ្លាដែលមាន។ អាចធ្វើជីកំប៉ុសតិចតួចនៅក្នុងសម្ភារៈដាក់របស់របរនៅតាមផ្ទះ ឬក្រុមហ៊ុនជំនួញ។ កន្លែងធ្វើជីកំប៉ុសធំៗ អាចបង្កើតឡើងនៅក្នុងទីក្រុង និងនៅកសិដ្ឋាន ដែលមានទីធ្លាសម្រាប់ជីករណ្តៅកាកសំណល់ធំ។

- <u>សម្ភារៈដែលស្ងួត ដែលអាចប្រើប្រាស់ឡើងវិញ និងដែលអាចកែច្នៃត្រូវបានបែងចែកនិងប្រើប្រាស់ឡើងវិញ កែច្នៃ ឬបញ្ជូនទៅរណ្តៅចាក់សំរាម</u>

ផលិតផលថ្មីៗជាច្រើនអាចផលិតយ៉ាងងាយចេញពីកាកសំណល់ដែលបានបោះចោលដូចជា៖

  - ចំពោះកង់ឡាន អ្នកអាចធ្វើជាស្បែកជើងសង្រែក ធុង និងជើងដាំរុក្ខជាតិ
  - ចំពោះសំបកកំប៉ុង អ្នកអាចធ្វើអំពូល ជើងដាំរុក្ខជាតិ និងប្រដាប់ដាក់ទៀន
  - ចំពោះប្រអប់អាហារលោងៗ អ្នកអាចធ្វើជាថង់ដាក់ទំនិញពេលទៅផ្សារ
  - ចំពោះសម្បកដូង អ្នកអាចធ្វើពែង សម និង ស្លាបព្រា
  - ចំពោះស្លឹកចេក អ្នកអាចធ្វើចានទាបនិងចានក្រឡូម
  - ចំពោះលោហៈសំណល់ អ្នកអាចធ្វើចង្រ្កាន អំពូល និងវត្ថុសិល្បៈ។

- <u>កាកសំណល់ពុលត្រូវការរៀបចំនិងបោះចោលយ៉ាងពិសេស</u>

ដោយសារតែការបោះចោលកាកសំណល់ពុលឲ្យមានសុវត្ថិភាព អាចជាការស្មុគស្មាញ និងចំណាយប្រាក់ច្រើន ដូច្នេះរដ្ឋាភិបាលគួរតែពង្រឹងគោលការណ៍សម្រាប់ការប្រើប្រាស់ រក្សាទុក និងបោះចោលសារធាតុពុល។ វាគួររួមបញ្ចូលការអប់រំ និងការបណ្តុះបណ្តាលសមាជិកសហគមន៍ អំពីការរៀបចំនិងបោះចោលកាកសំណល់ពុលឲ្យមានសុវត្ថិភាព។ គោលការណ៍នៃការរៀបចំកាកសំណល់ពុលដែលងាយអនុវត្តបានមានដូចខាងក្រោម៖

  - រក្សាទុកផលិតផលពុលឲ្យនៅឆ្ងាយពីអាហារនិងទឹក និងឆ្ងាយផុតពីដៃកុមារ
  - ដាក់ផលិតផលពុលនៅក្នុងធុងដើមរបស់វា និងមិនត្រូវលុបស្លាកសញ្ញាឡើយ បែបនេះជួយបង្ការកុំឲ្យប្រើប្រាស់ធុងឡើងវិញសម្រាប់ដាក់ទឹក ឬអាហារ
  - ដាក់កាកសំណល់ពុលដាច់ដោយឡែកពីកាកសំណល់តាមផ្ទះ
  - កុំដុតកាកសំណល់ពុល(បែបនេះធ្វើឲ្យសារធាតុគីមីរាលដាលតាមរយៈផេះផ្សែង ហើយជួនកាលវាបង្កើតជាសារធាតុគីមីទម្រង់មួយទៀតដែលកាន់តែគ្រោះថ្នាក់

- កុំចាក់សារធាតុពុលចូលក្នុងបង្គន់ លូបង្ហូរ ប្រឡាយទឹក ក្នុងផ្លូវទឹក ឬលើដី។

### ១.២.១.ការទាញយកប្រយោជន៍ពីសំរាម

ជាការពិតណាស់មនុស្សតែងតែយល់ឃើញថាសំរាមគឺជារបស់ដែលគេបោះបង់ចោលលែងត្រូវការនិងគ្មានប្រយោជន៍ តែការពិតទៅសំរាមក៏វាមានប្រយោជន៍របស់វាដែរនៅពេលដែលយើងយកវាទៅកែច្នៃជារបស់របរផ្សេងៗនិងវានៅមានប្រយោជន៍ជាច្រើនផ្សេងទៀតដូចជានៅក្នុងវិស័យកសិកម្មយើងអាចយកសំរាមមកកែច្នៃធ្វើជាជីកំប៉ុសជាដើម។

- *<u>ការទាញយកប្រយោជន៍ពីសំរាមយើងអាចធ្វើការបម្លែងសំរាមនោះទៅជាថាមពល</u>*

តាមរយៈការផ្តល់មូលនិធិដោយ សហភាពអឺរ៉ុប SWITCH-Asia អង្គការ SNV[1] កម្ពុជា បានអនុវត្តគម្រោងប្រែក្លាយសំណល់ទៅជាថាមពលសម្រាប់ប្រើប្រាស់ក្នុងរោងកិនស្រូវ (បច្ចេកវិទ្យាដើម្បីបម្លែងថាមពលអគ្គីសនីពីអង្កាម) ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៥។ គម្រោងនេះបានសម្រេចជ្រើសរើសខេត្តគោលដៅនៅទូទាំងប្រទេសកម្ពុជាចំនួន៩មានដូចជា៖ ខេត្តបាត់ដំបង ពោសាត់ កំពង់ស្ពឺ បន្ទាយមានជ័យ កំពង់ធំ សៀមរាប កណ្តាល កំពង់ចាម និងព្រៃវែង។ គម្រោងនេះមានគោលបំណងធ្វើឲ្យ វិស័យឧស្សាហកម្មកាន់តែមានពណ៌បៃតង កាន់តែស្អាត និងកាន់តែប្រកួតប្រជែង។

- *<u>ផលប្រយោជន៍ដែលបានពីការកែច្នៃសំរាម</u>*

កាកសំណល់សំរាមដែលសល់ពីការប្រើប្រាស់លោកអ្នកប្រាកដជាយកទៅបោះចោលដោយមិនធ្លាប់គិតថារបស់ទាំងនោះអាចនៅមានតម្លៃពេលក្រោយឡើយ។ ជាការពិតសំរាមនិងកាកសំណល់ទាំងអស់សុទ្ធតែមានគុណសម្បត្តិដោយឡែកមួយផ្សេងទៀតបន្ទាប់ពីត្រូវបានយកទៅកែច្នៃ។

*សំរាម* គឺជាវត្ថុដែលមនុស្សប្រើប្រាស់ហើយ រួចយកទៅ បោះចោលលែងត្រូវការ។ ឯសំរាមកែច្នៃ គឺជាការយកកាកសំណល់សំរាមទាំងនោះយកទៅច្នៃជាគុណប្រយោជន៍ជារបស់ប្រើប្រាស់និងគ្រឿងតាំងលម្អផ្សេងៗទៀត។ សំរាមដែលយកមកកែច្នៃ បានមកពីគ្រប់មជ្ឈដ្ឋាន គ្រប់ទីកន្លែង ដូចជា គេហដ្ឋាន រោងចក្រ សហគ្រាស ក្រុមហ៊ុន ទីផ្សារ វត្តអារាម ភោជនីយដ្ឋាន សណ្ឋាគារជាដើម និងតាមទីសាធារណៈផ្សេងទៀតដូចជា សួនច្បារ មាត់ទន្លេជាដើម ក៏គេអាចប្រមូលសំរាមបានដែរ។ សំរាម ឬ កាកសំណល់ ដែលយកមកប្រើសម្រាប់ធ្វើការកែច្នៃ បែងចែកចេញជាពីរប្រភេទគឺ សំរាមស្ងួត និងសំរាមសើម។

- *<u>សំរាមសើម</u>*៖ ជាសំរាមដែលផ្ទាប់ទឹក មានជាតិទឹក ឬមានសំណើមដូចជា កាកសំណល់ ផ្ទះបាយ កាកអំពៅ កាកដូង បន្លែ ផ្លែឈើ ដែលរលួយ កាកសំណល់ចេញពីទីផ្សារជាដើម។
- *<u>សំរាមស្ងួត</u>* ៖ សំរាមស្ងួត អាចចែកជាពីរប្រភេទផ្សេងទៀតផងដែរគឺ ប្រភេទស្រាល និង ប្រភេទធ្ងន់ ឬ រឹង។ សំរាមស្ងួតប្រភេទស្រាលមានដូចជា ក្រដាសកាសែត សៀវភៅ ទស្សនាវដ្ដី ថង់ប្លាស្ទិច ជ័រកៅស៊ូ សម្បកកំប៉ុងជាដើម និងរបស់របរជាច្រើនផ្សេងទៀត ដែលអាចយកមកកែច្នៃទៅតាមតម្រូវការនិង

ចំណាង់ចំណូលចិត្ត។ ចំណែកឯសំរាមប្រភេទធ្ងន់ ឬ រឹង មានដូចជា សម្បកកង់ឡាន អំបែងកែវ សម្បកដប ដែក និង ប្រភេទលោហៈធាតុដូចជា ឆ្នាំងបែកបាក់ ជាដើម។

របៀបកែច្នៃសំរាម ៖ សំរាម ដែលប្រមូលបានដោយអ្នករើសសំរាមត្រូវធ្វើការបែងចែកទៅតាមប្រភេទសំរាមនីមួយៗ។ សំរាមខ្លះ យកទៅកែច្នៃដោយគ្រឿងម៉ាស៊ីន(ម៉ាស៊ីនកិនកំប៉ុង)ប៉ុន្តែភាគច្រើនធ្វើដោយដៃផ្ទាល់។ របៀបកែច្នៃ គឺជា ការយកសំរាមនិងកាកសំណល់ដែលប្រើប្រាស់ហើយទៅធ្វើជារបស់ផ្សេងៗហើយដែលអាស្រ័យទៅលើការរចនានិងការច្នៃប្រឌិតឲ្យចេញជារូបរាងការនិយមចូលចិត្តនិងទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ឯប្រភេទសំរាមស្ងួតរឹងមួយចំនួន ត្រូវយកទៅស្លដោយម៉ាស៊ីន ទើបយកទៅកែច្នៃទៅតាមប្រភេទសំរាមនីមួយៗ។

ផលិតផលបានពីការកែច្នៃ ៖ លោកអ្នកប្រហែលជាធ្លាប់គិតថា សំរាមជាវត្ថុគ្មានប្រយោជន៍និងជារបស់ដែលគេបោះចោល។ សម្រាប់ប្រទេសជឿនលឿនគេអាចយកសំរាមទៅកែច្នៃបានជាប្រយោជន៍ច្រើនប្រការ។ បច្ចុប្បន្នប្រទេសកម្ពុជា ក៏កំពុងតែទាញយកប្រយោជន៍ដ៏ច្រើនពីការកែច្នៃសំរាមនិងកាកសំណល់ដែលប្រើប្រាស់រួចផងដែរ។

- ✓ *<u>កាកសំណល់សើម</u>* ៖ សំណល់ផ្ទះបាយ កាកអំពៅ កាកដូង បន្លែ និងផ្លែឈើរលួយ អាចយកទៅធ្វើជាដីកំប៉ុសសម្រាប់ស្រោចស្រព ទៅលើដំណាំ កសិកម្ម ស្រែចំការជាដើម។
- ✓ *<u>កាកសំណល់ស្ងួត</u>* ៖ អាចយកទៅកែច្នៃបានជា របស់របរច្រើនយ៉ាង ជាសម្ភារៈប្រើប្រាស់ក្នុងការិយាល័យនិងអាចប្រើជាលម្អក្នុងគេហដ្ឋានបានគ្រប់ផ្នែក។ ក្រដាស និង ថង់ប្លាស្ទិក អាចកែច្នៃធ្វើជាស៊ុមរូបថត ស្រោមសំបុត្រ កាតជូនពរ សឺមីសម្រាប់ដាក់ឯកសារ គ្រឿងអលង្ការ ធ្វើជាកន្ត្រក មួកកម្រាល តុ កាបូប ស្រោមទូរស័ព្ទ ប្រដាប់ជូតជើងជាដើម។ សម្បកកង់ឡាន និងកង់ម៉ូតូអាចយកទៅធ្វើជាថូផ្កា ធុងដាក់សំរាម ថូដាក់ប៊ិចជាដើម។ សម្បកដបនិងអំបែងកែវដែលខូចអាចយកទៅស្លហើយផលិតជាដបនិងកែវសម្រាប់ប្រើប្រាស់វិញបាន។ ដូចគ្នានិងការស្លលោហៈធាតុផ្សេងៗដើម្បីផលិតបានជាផលិតផលសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ។ ក្រៅពីនេះនៅមានផលិតផលជាច្រើនទៀតដែលកើតចេញពីការយកសំរាមឬកាកសំណល់ទៅកែច្នៃ។

**<u>ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការកែច្នៃសំរាម</u>**

សំរាមគ្រប់ប្រភេទ ដែលប្រមូលបានក៏អាស្រ័យលើការចូលរួមពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានហើយនេះក៏ជាយុទ្ធសាស្ត្រមួយក្នុងការសន្សំបន្ថែមលើផ្នែកសេដ្ឋកិច្ចគ្រួសារ។ ពួកគាត់អាចយកសំរាមទាំងនោះទៅលក់ឲ្យអ្នកទិញអេតចាយ ហើយអ្នកទិញអេតចាយឬអ្នករើសសំរាមអាចប្រមូលរបស់ទាំងនោះទៅលក់បន្តទៀតដើម្បីជាការដោះស្រាយបញ្ហាជីវភាពក្នុងគ្រួសារ។

ការកែច្នៃសំរាមមានគុណសម្បត្តិច្រើនជាងគុណវិបត្ត។ ទន្ទឹមនិងផលិតផលច្រើនប្រការដែលកើតចេញពីការកែច្នៃសំរាមកិច្ចការនេះក៏ផ្តល់ជាគុណសម្បត្តិច្រើនប្រការផងដែរ។ ដែលគុណសម្បត្តិទាំងនោះមានដូចខាងក្រោមៈ

- ✓ ការកែច្នៃសំរាមអាចបង្កើតជាមុខរបរសម្រាប់ប្រជាពលរដ្ឋដែលក្រីក្រ ដូចជាអ្នករើសអេតចាយជាដើម។ ម្យ៉ាងទៀតវាអាចធ្វើឲ្យអ្នកទាំងនោះមានជំនាញមួយពិតប្រាកដប្រចាំជីវិត។ ហើយទៅថ្ងៃអនាគតពួកគាត់អាចយកចំណេះនេះទៅចិញ្ចឹមជីវិតបានថែមទៀតផង។
- ✓ ការកែច្នៃសំរាមជួយបង្កើនចំណូលសេដ្ឋកិច្ចគ្រួសារ។ តាមរយៈលទ្ធផលទាំងអស់នេះអ្នករើសសំរាមអាចទទួលបានប្រាក់កម្រៃសម្រាប់ផ្គត់ផ្គង់ជីវភាព។
- ✓ ផលិតផលដែលកើតចេញពីការកែច្នៃសំរាមប្រើជាគ្រឿងលម្អគេហដ្ឋាននិងផលប្រយោជន៍ក្នុងការងារផងដែរ។



ការកែច្នៃសំរាមទៅជាធុងដាក់សំរាមដែលជាស្នាដៃកូនខ្មែរ

ការកែច្នៃសំរាមពុំមានផលប៉ះពាល់អ្វីធ្ងន់ធ្ងរនោះឡើយ ព្រោះសំរាមទាំងអស់សុទ្ធតែឆ្លងកាត់ការសម្អាតដោយទឹកសាប៊ូរួចហើយ។ ប៉ុន្តែវាអាចមានគ្រោះថ្នាក់ដល់សុខភាពបន្តិចបន្តួចនៅពេលដែលអ្នករើសសំរាមទាំងនោះដើររើសនិងប្រមូលសំរាមដូចជាមានកន្ទួលរមាស់ ជំងឺសើស្បែក បញ្ហាផ្លូវដង្ហើម ដែលបណ្តាលមកពីក្លិនមិនល្អពីសំរាមជាដើម។

## ១.២.២.ការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក

សំណល់ប្លាស្ទិកក្នុងប្រទេសកម្ពុជាបានកើនឡើងដោយសារតែកំណើនប្រជាពលរដ្ឋ កំណើនជីវភាពនិងសេដ្ឋកិច្ចការផ្លាស់ប្តូរឥរិយាបទក្នុងការប្រើប្រាស់ និងការប្រើប្រាស់ប្លាស្ទិកសម្រាប់វេចខ្ចប់ម្ហូបអាហារឬ សម្ភារផ្សេងៗ និងកង្វះខាតចំណេះដឹងក្នុងការញែកសំរាម។

ដំណោះស្រាយដែលល្អបំផុត ដើម្បីកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក និងការផលិតសំណល់ គឺត្រូវប្រើប្រាស់យុទ្ធសាស្ត្រ 4Rs ៖

- បដិសេធមិនប្រើប្រាស់ (Refuse)៖ រាល់ប្លាស្ទិកដែលប្រើប្រាស់តែម្តងទាំងអស់ ដូចជាបំពង់បឺត កែវ ថង់ដប ប្រអប់ស្នោដាក់អាហារដែលធ្វើប្លាស្ទិក

- កាត់បន្ថយ (Reduce)៖ ធ្វើការសម្រេចចិត្តទិញដែលមិនប៉ះពាល់ដល់បរិស្ថាន មុនពេលទិញផលិតផលប្លាស្ទិក
- ប្រើប្រាស់ឡើងវិញ (Reuse)៖ ប្រើប្រាស់ប្លាស្ទិកចាស់ជាជាងទិញប្លាស្ទិកថ្មី
- កែច្នៃ (Recycle)៖ កែច្នៃនិងចោលប្លាស្ទិកប្រកបដោយការទទួលខុសត្រូវ ជានិច្ចកាលត្រូវប្រើធុងសំរាម

*ផលប៉ះពាល់របស់ប្លាស្ទិក*

❖ ***ការបំពុលដោយប្លាស្ទិកបង្កផលប៉ះពាល់អវិជ្ជមានដល់បរិស្ថានរបស់យើង*** សំណល់ប្លាស្ទិក អាចបង្កផលប៉ះពាល់អវិជ្ជមានដល់បរិស្ថានជុំវិញ ជីវចម្រុះ សុខភាពមនុស្ស ក៏ដូចជាសេដ្ឋកិច្ចរបស់ប្រទេស។

✓ បង្កឲ្យមានទឹកជំនន់ដែលផ្តល់ផលវិបាកនិងការខូចខាតធ្ងន់ធ្ងរ ៖ សំណល់ប្លាស្ទិកអាចបង្កឲ្យមានទឹកជំនន់ ដោយសារតែវាធ្វើឲ្យស្ទះផ្លូវទឹក និងស្ទះលូទឹកស្អុយ និងប្រព័ន្ធបង្ហូរទឹក ដូចក្នុងករណីទឹកជំនន់នៅប្រទេសបង់ក្លាដែស។ កាលពីឆ្នាំ២០០២ប្រទេសបង់ក្លាដែស ក្លាយជាប្រទេសទី១នៅក្នុងពិភពលោកដែលដាក់បំរាមមិនឲ្យប្រើប្រាស់ថង់ប្លាស្ទិក ក្រោយពេលដែលថង់ប្លាស្ទិក ធ្វើឲ្យស្ទះប្រព័ន្ធលូពេលគ្រោះទឹកជំនន់ដែលបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ប្រទេសនេះ។

✓ ការបំពុលបរិស្ថានសមុទ្រដោយសារប្លាស្ទិក បង្កផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី សមុទ្រ ទន្លេ បឹងបួរ ជីវចម្រុះនិងមនុស្ស ៖ បច្ចុប្បន្ននេះ សំរាមភាគច្រើននៅក្នុងសមុទ្ររបស់យើងគឺសំរាមប្លាស្ទិក។ ជារៀងរាល់ឆ្នាំប្លាស្ទិកប្រមាណ៨លានតោនហូរចូលទៅក្នុងសមុទ្រតាមរយៈទន្លេធំៗចំនួន១០។ ទន្លេចំនួន៨ក្នុងចំណោមទន្លេទាំង១០នេះគឺស្ថិតនៅអាស៊ី ដែលក្នុងនោះទន្លេមួយ គឺទន្លេមេគង្គ។ ប្លាស្ទិកផ្លាស់ទីពីដីទៅក្នុងទន្លេដោយសារការបោះចោលទៅក្នុងទន្លេ ឬតាមរយៈខ្យល់បក់ ហើយចុងក្រោយវាធ្លាក់ចូលទៅក្នុងសមុទ្រ។ នៅតំបន់សមុទ្រ ថនិកសត្វ ត្រីនិងបក្សីជាច្រើន រងផលប៉ះពាល់ដោយសារការស៊ីប្លាស្ទិក ឬជាប់ទាក់ទងនិងប្លាស្ទិក ។ កន្លងមកមានសត្វសមុទ្រជាប់ទាក់ទងនិងសម្ភារប្លាស្ទិក ចំនួនជាង៣៤៤ករណីដែលត្រូវបានរាយការណ៍ ជារៀងរាល់ឆ្នាំមានបក្សីសមុទ្រចំនួនជាង១លានក្បាលនិងសត្វសមុទ្រចំនួន១០០.០០ក្បាលបាត់បង់ជីវិត ដោយសារច្រឡំស៊ីប្លាស្ទិក ជាចំណី។ ប្រព័ន្ធអេកូឡូស៊ីផ្កាថ្មក៏រងប៉ះពាល់ដោយសារទទួលរងការសឹករិចរិលនិងការខូចខាតបង្កឡើងដោយសារឧបករណ៍នេសាទដែលធ្វើពីប្លាស្ទីកផងដែរ។

❖ ***ការបំពុលដោយសារប្លាស្ទិក បង្កផលប៉ះពាល់ជាអវិជ្ជមានដល់សុខភាពរបស់យើង***

✓ ប្លាស្ទិកចូលទៅក្នុងខ្លួនមនុស្ស តាមរយៈត្រីដែលយើងបរិភោគ ៖ ប្លាស្ទិកភាគច្រើននៅក្នុងសមុទ្រ បំបែកជាតុបន្តិចម្តងៗជាកម្ទេចតូចៗ ដែលមានប្រវែងក្រោម ៥ មីលីម៉ែត្រ ដែលគេហៅថា " មីក្រូប្លាស្ទិក "។ បក្សី និងត្រីជាង៩០% ត្រូវបានរាយការណ៍ថា មានផ្ទុកកម្ទេចតូចៗ ក្នុងពោះរបស់វា។ សារធាតុពុលទាំងនេះ កើនឡើងបន្តិចម្តងៗ និងហូរចូលមកក្នុងសង្វាក់អាហារពីត្រីទៅមនុស្ស។

✓ <u>ផ្សែងពុលពីការដុតប្លាស្ទិក អាចបង្កបញ្ហាផ្លូវដង្ហើម រួមនឹងជម្ងឺមហារីក</u> ៖ ប្លាស្ទិកដែលត្រូវបានគេដុត ក៏បង្កការគំរាមកំហែងដល់សុខភាពរបស់មនុស្ស សត្វ និងរុក្ខជាតិផងដែរ ព្រោះថាវាបញ្ចេញសារធាតុគីមីដែលមានគ្រោះថ្នាក់ ដូចជាឧស្ម័ន កាបូនិក (CO2) ឌីអុកស៊ីន (Dioxins) និងហ្វូរ៉ង់ (Furans) ជាដើម។ នៅពេលមនុស្សស្រូបយកសារធាតុគីមីទាំងនេះពីផ្សែង វាអាចបង្កឲ្យមានជម្ងឺផ្លូវដង្ហើម ហើយក៏អាចបង្កជម្ងឺមហារីក។ ការបំភាយឧស្ម័នពុលពីការដុតប្លាស្ទិកទាំងនោះបានរួមចំណែកធ្វើឲ្យមានបម្រែបម្រួលអាកាសធាតុផងដែរ។

❖ ***<u>ការចំណាយសេដ្ឋកិច្ចខ្ពស់សម្រាប់សម្អាតការបំពុលដែលបង្កឡើងដោយប្លាស្ទិក</u>*** ការខូចខាតដល់សេដ្ឋកិច្ច ដែលបង្កឡើងដោយសំណល់ប្លាស្ទិកមានទំហំធំធេង។ នៅពេលដែលប្លាស្ទិកត្រូវបានចោលទៅក្នុង សមុទ្រ វាបង្កការខូចខាតដល់ជីវិតសត្វ ដែលរស់នៅក្នុងសមុទ្រនិងប្រព័ន្ធអេកូឡូស៊ីដែលទាមទារឲ្យមានការអន្តរាគមន៍ពី រដ្ឋាភិបាលដើម្បីសម្អាត ហើយការសម្អាតបែបនេះត្រូវការចំណាយដ៏ខ្ពស់។ ប្លាស្ទិកមួយចំនួន មិនងាយយកមកធ្វើការកែច្នៃ ដើម្បីប្រើប្រាស់ឡើងវិញឡើយហើយការសម្អាត ប្លាស្ទិកដែលប្រើប្រាស់បានតែម្តងរួចបោះចោល នៅក្នុងបរិស្ថាន ត្រូវការ ការចំណាយខ្ពស់ និងការប្រើប្រាស់ធនធានដ៏ច្រើន។ ការខូតខាតផ្នែកសេដ្ឋកិច្ចសរុប ដែលបង្កមកលើប្រព័ន្ធអេកូឡូស៊ីសមុទ្ររបស់ពិភពលោកដោយសារប្លាស្ទិកកើនឡើងដល់យ៉ាងហោចណាស់ ១៣ ពាន់លានដុល្លារជារៀងរាល់ឆ្នាំ។

ផ្ទុយទៅវិញសំរាមប្លាស្ទិកអាចក្លាយជាវត្ថុមានតម្លៃក្នុងការជំរុញឲ្យសេដ្ឋកិច្ចជាតិមានការកើនឡើង តាមរយៈការអនុវត្តសេដ្ឋកិច្ចចក្រា ដោយការកែច្នៃសំរាមប្លាស្ទិកទាំងនោះឲ្យទៅជាថាមពលអគ្គិសនី សម្ភារប្រើប្រាស់ឡើងវិញ និងកាត់បន្ថយការចំណាយក្នុងការទិញសម្ភារប្លាស្ទិកថ្មី។

បញ្ហាប្លាស្ទិកនឹងត្រូវដោះស្រាយលុះត្រាតែមានការចូលរួមពីយើងទាំងអស់គ្នា។ ខាងក្រោមនេះជាវិធីដែលអ្នកអាចចូលរួមកាត់បន្ថយប្លាស្ទិក៖

- យកថង់ដែលអាចប្រើប្រាស់ឡើងវិញ ឬថង់បរិស្ថានតាមខ្លួនសម្រាប់ទិញទំនិញ ឬវេចខ្ចប់អាហារ
- យកដបទឹកដែលអាចប្រើប្រាស់ឡើងវិញតាមខ្លួនជានិច្ច
- យកដបទឹក ឬកែវខ្លួនឯងមកប្រើប្រាស់ជាប្រចាំ
- ប្រើប្រាស់បំពង់បឺត ឬកំបិត ស្លាបព្រា សមធ្វើពីសារធាតុដែលអាចរលាយក្នុងបរិស្ថាន
- វេចខ្ចប់អាហាររបស់អ្នក ដោយប្រើប្រាស់ប្រអប់ដែលប្រើប្រាស់ឡើងវិញ ឬសម្ភារមិនមែនប្លាស្ទិក
- ចៀសវាងទិញអាហារឬម្ហូប ដែលវេចខ្ចប់ថង់ប្លាស្ទិកច្រើន
- បំពេញម្សៅសាប៊ូឡើងវិញនៅកន្លែងលក់ ដោយមិនបាច់ទិញដបសាប៊ូថ្មី។

## ១.៣.មូលហេតុនៃកំណើនបរិមាណសំរាម និងវិធីសាស្ត្រនៃការគ្រប់គ្រងសំរាមនៅកម្ពុជា

កំណើនបរិមាណសំរាមបណ្តាលមកពីកំណើនចំនួនប្រជាជន កំណើនកម្រិតជីវភាពរស់នៅ កំណើននគរូបនីយកម្ម និងឧស្សាហកម្ម។ ម្យ៉ាងវិញទៀតការកើនឡើងនូវកាកសំណល់សំរាមដោយសារតែកំណើនសេដ្ឋ

កិច្ចប្រើប្រាស់ច្រើនមានការវេចខ្ចប់ច្រើន ហើយចំណុចមួយទៀតគឺការកែច្នៃនៅមានកម្រិតធ្វើឲ្យកំណើនក៏កើនឡើង។ បើសិនយើងកែច្នៃបានសំរាមច្រើន គឺសំរាមមិនមានការកើនឡើងនោះទេ។ ដើម្បីដោះស្រាយបញ្ហានេះបានយើងគួរតែជំរុញឲ្យមានការកែច្នៃសំរាម ១០០% ដែល ៦៨%ជាសំណល់សរីរាង្គ ដែលអាចធ្វើជីកំប៉ុសបាន។ ឯថង់ប្លាស្ទិកយើងអាចកែច្នៃប្រើប្រាស់បានឡើងវិញ កែច្នៃជាវត្ថុ ឬក៏ប្រើប្រាស់ឡើងវិញបាន។ ជាពិសេសយើងត្រូវអប់រំដល់ប្រជាពលរដ្ឋឲ្យគាត់កាត់បន្ថយការប្រើប្រាស់ ឬក៏ការញែកសំរាមឲ្យបានទៀងទាត់ ត្រឹមត្រូវដែលគាត់មានដីអាចបង្កើតជាជីកំប៉ុសបានឬ ក៏ប្រើប្រាស់ជាជីដាក់ផ្កាបានសម្រាប់សំណល់សរីរាង្គ។

ចំពោះវិធីសាស្ត្រនៃការគ្រប់គ្រងគឺ ប្រជាជនកម្ពុជាភាគច្រើន ហាក់បីដូចជាមានការយល់ដឹងតិចតួចអំពីរបៀបនៃការចោលសំណល់ឲ្យបានត្រឹមត្រូវ។ ហេតុនេះ ដោយសារតែគេសង្កេតឃើញថា នៅតែមានសំរាម ឬសំណល់រឹងយ៉ាងច្រើនបោះចោលតាមកន្លែងទីសាធារណៈ តាមដងផ្លូវ ឬនៅតាមកន្លែងទំនេរនៅក្បែរអគារលំនៅដ្ឋាន។ ជាងនេះទៅទៀត នៅទីក្រុងនិងទីប្រជុំជន ជាច្រើននៅតាមខេត្ត នៅតែមានការខ្វះខាតប្រព័ន្ធសមស្របមួយដើម្បី ប្រមូល ដឹកជញ្ជូន និងកម្ចាត់ចោលនូវសំណល់រឹងឲ្យបានត្រឹមត្រូវ។

### ១.៣.១.វិធីសាស្ត្រនៃការគ្រប់គ្រងសំរាមដែលប្រើដោយប្រជាពលរដ្ឋ

ប្រជាជនកម្ពុជា បានបោះចោលសំរាមទៅតាមវិធីផ្សេងៗគ្នា។ ប្រជាជនកម្ពុជា តែងតែបែងចែកសំណល់រឹងនៅនឹងកន្លែងកកើតសំរាម។ ការញែកសំណល់ដែលអាច កែច្នៃវិញបានគឺធ្វើឡើងដោយមានការស្ម័គ្រចិត្ត។ អ្នករើសសំរាមក៏ដើរតួនាទីផង ដែរក្នុងការបែងចែកសំណល់ដែលអាចលក់បានពីក្នុងធុងសំរាម និងនៅកន្លែងដែលចោលសំរាម។ ការគ្រប់គ្រងសំរាមត្រូវបានអនុវត្តដោយមនុស្សជាច្រើន គឺតាមរយៈការដុត។ ខណៈពេលដែលការដុតសំរាមក្នុងទីក្រុងកម្រ នឹងធ្វើឡើង វាត្រូវបានគេសង្កេតឃើញថាមនុស្សជាច្រើននៅក្នុងតំបន់ជនបទមាននិន្នាការទៅលើការដុតសំរាមដោយពួកគេយល់ឃើញថាវាជាវិធីសាស្ត្រងាយស្រួលជាងក្នុងការយកសំរាមទៅចោល។ នេះគឺជាឆ្លុះបញ្ចាំងពីការពិត ផងដែរថាការផ្តល់សេវាប្រមូលសំរាម នៅមានកម្រិត និងខ្វះទីលានចាក់សំរាមនៅតាមទីជនបទ។ ទាំងនេះបណ្តាលឲ្យមានការប្រតិបត្តិវិធីផ្សេងៗគ្នានៃការគ្រប់គ្រងសំរាមនៅតាមទីជនបទ រួមមាន ការដុតបំផ្លាញ (៦៦%) ការកប់នៅជិត ឬនៅពីក្រោយផ្ទះ (១១%) ការចោលសំរាមទៅក្នុងវាលស្រែនៅតាមផ្លូវសាធារណៈ (៩%) និងនៅតាមកន្លែងទំនេរ ការចោលសំរាមចូលទៅក្នុងទឹក (៥%) និងកន្លែងផ្សេងៗទៀត (៩%)។

### ១.៣.២.វិធីសាស្ត្រនៃការគ្រប់គ្រងសំរាមដែលប្រើដោយស្ថាប័នរដ្ឋបាលឬ អាជ្ញាធរមូលដ្ឋាន

❖ *ទីលានចាក់សំរាម*

សំរាមជាច្រើន ត្រូវបានបោះចោលនៅកន្លែងចាក់សំរាម ឬសំណល់ ( ដូចជា នៅទីលានចាក់សំរាមដង្កោនៅទីក្រុងភ្នំពេញ នៅទីលានចាក់សំរាមនៅខេត្តកំពត និងនៅទីលានចាក់សំរាមនៅខេត្តផ្សេងៗទៀត)។ គេសង្កេតឃើញថាមានប្រហែលជា ៦០កន្លែងសម្រាប់ចាក់សំរាមកំពុងដំណើរការនៅទូទាំងប្រទេសកម្ពុជា ប៉ុន្តែភាគច្រើននៃតំបន់ទាំងនេះ ត្រូវបានគេដឹងថា មានគុណភាពអន់ហើយការរចនាបច្ចេកទេសនៅមានកម្រិត។

ករណីលើកលែងមួយ គឺនៅរាជធានីភ្នំពេញ នៅឆ្នាំ២០០៩ ទីលានចាក់សំរាមដង្កោ ត្រូវបានសាងសង់ឡើង ដោយប្រើប្រាស់បច្ចេកទេសទំនើបរួមបញ្ចូលគ្នា រួមទាំងប្រព័ន្ធបង្រួម ឬសង្កត់សំរាមនិង ប្រព័ន្ធបង្ហូរទឹកស្អុយ។

❖ *ការកែច្នៃ*

ក្រៅពីទីលានចាក់សំរាម រដ្ឋាភិបាល(មូលដ្ឋាន) ធ្វើកិច្ចសហប្រតិបត្តិការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងវិស័យពាក់ព័ន្ធ នឹងការគ្រប់គ្រងសំរាម ឬសំណល់នេះ បានអនុវត្តការធ្វើជីកំប៉ុស និងកម្មវិធីកែច្នៃជាច្រើន។

ការធ្វើជីកំប៉ុសពីសំរាម និងការកែច្នៃសំរាម ត្រូវបានបង្កើតឡើងនៅក្នុងទីក្រុង និងនៅតាមបណ្ដាខេត្តមួយចំនួននៃប្រទេសកម្ពុជា។ ជាក់ស្ដែងនៅក្នុងខេត្តបាត់ដំបង រោងចក្រធ្វើជីកំប៉ុសមួយត្រូវបានប្រតិបត្តិការនៅជិតទីលានចាក់សំរាម។ រោងចក្រនេះត្រូវបានគាំទ្រផ្នែកហិរញ្ញវត្ថុ ដោយក្រសួងអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់សហព័ន្ធអាល្លឺម៉ង់ និងសហគមន៍ Thuringian កម្ពុជានិងត្រូវបានប្រតិបត្តិដោយអង្គការមិនមែនរដ្ឋាភិបាល។ ចំណែកនៅទីក្រុងភ្នំពេញគម្រោងជីកំប៉ុសត្រូវបានអនុវត្តដោយ អាជ្ញាធរគ្រប់គ្រង់សំរាមភ្នំពេញ ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ដូចជា អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED) និងអង្គការស្ការ៉ូ (SCARO)។ អាជ្ញាធរគ្រប់គ្រង់សំរាម គឺទទួលខុសត្រូវលើការប្រមូលសំរាម ឬសំណល់សរីរាង្គរឹង នៅតំបន់ដែលបានកំណត់ និងផ្គត់ផ្គង់សំរាមទាំងនេះទៅអង្គការកែច្នៃសំរាមនិងសិក្សានៅកម្ពុជា និងអង្គការស្ការ៉ូ សម្រាប់គម្រោងជីកំប៉ុស។ ជាងនេះទៅទៀតអាជ្ញាធរគ្រប់គ្រង់សំរាមភ្នំពេញក៏បានផ្ដល់ទីតាំងនៅឯទីលានចាក់សំរាម ទៅអង្គការកែច្នៃសំរាមនិងសិក្សានៅកម្ពុជាផងដែរ ដើម្បីអនុវត្តគម្រោងធ្វើជីកំប៉ុស។

❖ *ឡដុត ឬរោងចក្រដុតសំរាម*

ការចោលសំរាម ឬសំណល់វេជ្ជសាស្ត្រ ត្រូវបានចោលតាមរយៈឡដុតសំរាម។ ទាក់ទងទៅនឹងឡដុតសំណល់វេជ្ជសាស្ត្រ មន្ទីរពេទ្យ ពហុគ្លីនិក គ្លីនិក និងមណ្ឌលសុខភាព ដែលមិនមានឡដុតបញ្ជូនសំរាម ឬសំណល់ ទៅកាន់មន្ទីរពេទ្យដែលមានឡដុតនៅនឹងកន្លែង។ ទោះជាយ៉ាងណាក៏ដោយ សំណល់វេជ្ជសាស្ត្រតិចតួចប៉ុណ្ណោះដែលមានបរិមាណ ប្រមាណជា ៣៥៧គីឡូក្រាម និង៦៨លីត្រ ត្រូវបានគេរាយការណ៍ថាត្រូវបានដុតជាប្រចាំថ្ងៃដោយឡដុតសំរាមនៅនឹងកន្លែងនៅតាមមន្ទីរពេទ្យតូចៗមួយចំនួន។ ផេះនិងសំរាម ឬសំណល់មួយចំនួនដែលបានបង្កើតពីការដុតរំលាយត្រូវបានបោះចោលនៅកន្លែងនៅក្នុងតំបន់ជុំ វិញនៃការដុតនេះ ខណៈពេលដែលផ្នែកខ្លះដែលនៅសល់ត្រូវបានប្រមូលដោយក្រុមហ៊ុន PSBK ដើម្បីបោះចោលនៅទីលានចាក់សំរាម។

## ១.៤.ផលប៉ះពាល់នៃការគ្រប់គ្រងសំរាម

### ១.៤.១. ការចោលសំរាមនៅទីសាធារណៈ

ទោះបីជាមានសេវាកម្មប្រមូល និងដឹកជញ្ជូនសំរាមនៅតាមតំបន់ប្រជុំជន និងនៅតាមទីរួមខេត្តនានានៅក្នុងប្រទេសកម្ពុជាក៏ដោយ គេសង្កេតឃើញថា ការចោលសំរាមនៅទីសាធារណៈនៅតែកើតមានឡើងនៅតាម

តំបន់ទាំងនេះ។ មានគំនរសំរាម ហើយនៅពេលមានភ្លៀងធ្លាក់មក គឺដូចជាការចម្រោះជាតិពុល គ្រប់បែបយ៉ាងឲ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឲ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធាតុធ្ងន់ និងជួនការមានបាក់តេរីកាចៗ ដែលនៅពេលនោះហើយនិងមានលេចឡើងនៅជំងឺរាគត្បាតផ្សេងៗដោយសារតែមានការទទួលទានទឹកមិនស្អាត។ វត្តមាននៃសំរាមតាមទីសាធារណៈក្នុងទីក្រុងក្នុងតំបន់ប្រជុំជនដែលមានប្រជាជនរស់នៅច្រើនអាចប៉ះពាល់សុខភាពមនុស្សយ៉ាងខ្លាំង។ សំរាមជាប្រភពនាំឲ្យមានសត្វល្អិត សត្វរុយ ជាពិសេសសត្វកណ្តុរដែលជាភ្នាក់ងារចម្លងជំងឺច្រើនមុខ។ សត្វកណ្តុរអាចចម្លងជំងឺមកមនុស្សដោយផ្ទាល់គឺតាមរយៈអាចម៍ ទឹកនោម ឬការខាំនិងដោយមិនផ្ទាល់តាមរយៈសត្វល្អិតដូចជាចៃ រុយ សង្កើច។

ទោះបីជា មិនមានការសិក្សាស្រាវជ្រាវជាក់លាក់ណាមួយទៅលើផលប៉ះពាល់នៃការចាក់សំរាម នៅទីសាធារណៈ នៅកម្ពុជាក៏ដោយជាទូទៅការចោលសំរាម នៅទីសាធារណៈ ហាក់បីដូចជាមានផលប៉ះពាល់ដូចខាងក្រោម៖

❖ ផលប៉ះពាល់លើបរិស្ថាន
 - សំរាមអាចសម្លាប់សត្វដែលមានជីវិត នៅក្នុងទឹកដោយផ្ទាល់និងដោយប្រយោល ព្រមទាំងធ្វើឲ្យប៉ះពាល់គុណភាពទឹក តាមរយៈការកាត់បន្ថយអុកស៊ីសែនដែលមានក្នុងផ្លូវទឹក។ ឧ.កន្ទុយបារីបញ្ចេញសារធាតុពុលដែលមានគ្រោះថ្នាក់ ទៅក្នុងទឹក នៅពេលដែលវាបំបែកធាតុ។
 - សំរាម ធ្វើឲ្យសោភ័ណភាពនៅតាមទីសាធារណៈ មានការធ្លាក់ចុះ។
 - សំរាម អាចធ្វើឲ្យមានការខូតខាតដល់ផ្លូវទឹក និងប្រព័ន្ធលូទឹក។ ឧ.គេសង្កេតឃើញថាការបោះចោល សំរាមដែលមិនរលួយអាចរាំងស្ទះបំពង់លូបង្ហូរទឹកនៅទីក្រុង ដែលចូលរួមចំណែកធ្វើឲ្យមានការលិចទឹកក្នុងទីក្រុង។

❖ ផលប៉ះពាល់លើសុខភាពមនុស្ស
 - ការចោលសំរាមនៅទីសាធារណៈ បណ្តាលឲ្យមានផលប៉ះពាល់ដល់សុខភាពសាធារណៈ ដោយសារតែ វាជាកន្លែងទាក់ទាញ សត្វល្អិតផ្សេងៗ និងជាកន្លែងបាក់តេរីបង្កាត់ពូជ
 - ការចោលសំរាមនៅទីសាធារណៈ ដូចជា កែវបែក និងសឺរាំង អាចមានគ្រោះថ្នាក់ធ្ងន់ធ្ងរសម្រាប់សុខភាពមនុស្ស។



ការចោលសំរាមនៅតាមទីសាធារណៈ

## ១.៤.២.ផលប៉ះពាល់នៃការដុតសំរាម

នៅតាមបណ្តាប្រទេសក្រីក្រ កំពុងអភិវឌ្ឍន៍ដែលពុំទាន់មានរចនាសម្ព័ន្ធប្រមូលសំរាមបានត្រឹមត្រូវនិងគ្រប់គ្រាន់ វិធីសាស្ត្រដ៏ប្រសើរជាងគេនិងដែលជាទម្លាប់របស់ប្រជាជនតាំងពីយូរយារណាស់មកហើយគឺការដុតកម្ទេច ប៉ុន្តែទង្វើបែបនេះមិនមែនជាជម្រើសល្អឡើយព្រោះការដុតសំរាមបានបញ្ចេញជាតិពុលជាធាតុល្អិតឆ្មារៗច្រើនណាស់។ សូម្បីតែការដុតសំរាមជាស្លឹកឈើដែលជនគ្រប់រូបគិតស្មានថាល្អតាមពិតជាការបំពុលបរិស្ថានខ្លាំងបំផុត។ សំរាមស្លឹកឈើ ៥០គីឡូក្រាម ដុតនៅទីវាលបញ្ចេញឧស្ម័នពុលស្មើនឹងការបើកឡានម៉ាស៊ូតចម្ងាយ ១មឺនបីពាន់គីឡូម៉ែត។ ជាតិពុលបន្សល់ទុកដោយការដុតសំរាមជាសារធាតុឆ្មារៗមានពីរយ៉ាង។ ទីមួយសារធាតុល្អិតឆ្មារៗតូចជាង(២,៥មីក្រូភីអឹម) ដូចជាការបញ្ចេញផ្សែងពុល ផ្សែងឡានម៉ាស៊ូត ដែលយើងនិយាយគ្រប់មាត់នៅពេលការបំពុលបរិយាកាសឡើងអ័ព្ទក្នុងក្រុង។ ជាតិពុលបែបនេះអាចបង្កផលប៉ះពាល់ខ្លាំងដល់អ្នកមានប្រព័ន្ធដកដង្ហើមខ្សោយ ធ្វើឲ្យមានជំងឺហឺត រលាកទងសួត និងអាចឈានដល់ថ្នាក់កើតជំងឺខ្សោយដង្ហើមរ៉ាំរ៉ៃ។ ទីពីរ ការដុតសំរាមជាការបញ្ចេញជាតិលោហៈធ្ងន់ ដូចជាលីតូនីញ៉ូម សំណ ដែលបង្កគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរខ្លាំងទៀត ព្រោះជាភ្នាក់ងារបង្កឲ្យមានជំងឺមហារីក បើយើងស្រូបជាតិពុលនេះក្នុងកម្រិតខ្ពស់និងក្នុងរយៈពេលយូរតគ្នាជាប់។

ចំពោះប្រជាជនកម្ពុជា ដែលរស់នៅតាមទីជនបទភាគច្រើនយកការដុតសំរាមជាវិធីសាស្ត្រមួយសម្រាប់ការកាត់បន្ថយបរិមាណសំរាមក៏ដោយ មានប្រជាជនកម្ពុជាមួយចំនួនយល់ឃើញថា ការដុតសំរាមបែបនេះប្រហែលជា មានផលប៉ះពាល់ជាអវិជ្ជមានដល់សុខភាពមនុស្ស និងបរិស្ថាន។

ជាទូទៅ ការដុតសំរាមនៅទីវាលនឹងមានផលប៉ះពាល់អវិជ្ជមានទៅលើសុខភាពមនុស្ស និងបរិស្ថាន ព្រោះថាការដុតសំរាមនៅទីវាល ឬនៅទីលានចាក់សំរាមនឹងបញ្ចេញនូវសារធាតុបំពុលខ្យល់និងផេះ ព្រមទាំងផ្សែងក្រាស់ ជាច្រើន។ ផេះដែលបានមកពីការដុតសំរាមទំនងជាលាយឡំ ជាមួយសារធាតុគីមីដែលមានជាតិពុល ដូចជា សារធាតុពុល ឌីអុកស៊ីន (dioxins) និងសារធាតុ ហ្វូរ៉ាន (furans) អ៊ីដ្រូកាបូន polycyclic (PAHs) និងសារធាតុដែលធ្វើឲ្យមានជម្ងឺមហារីកផ្សេងៗ។ លើសពីនេះទៀត ផ្សែងអាចមានសារធាតុ អាល់ដេហ៊ីដ (aldehydes) ជាតិអាស៊ីត ជាតិនីត្រូជែនអុកស៊ីត ស៊ុលហ្វួរអុកស៊ីត ជាតិអ៊ីដ្រូកាបូន polycyclic (PAHs) ឌីអុកស៊ីន (dioxins) ជាតិហ្វូរ៉ាន (furans) និងសារធាតុគីមីផ្សេងៗទៀត។

- ផលប៉ះពាល់លើសុខភាពមនុស្ស
  - វត្ថុដែលមានសារធាតុពុល អាចបណ្តាលឲ្យមានបញ្ហារលាក ព្រមទាំងមានបញ្ហាស្បែក និងផ្លូវដង្ហើម។ ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ទាំងនេះនឹងអាស្រ័យទៅលើ ចម្ងាយពីកន្លែងដុត រយៈពេលនៃការជិតកន្លែងដុតសំរាម បរិមាណ និងប្រភេទសំរាមដែលបានដុត និងភាពរំញោចរបស់មនុស្សម្នាក់ៗ
  - បុគ្គលដែលមានបញ្ហាផ្លូវដង្ហើម ដូចជាជម្ងឺ ហឺតឬ មានបញ្ហាអាលែហ្ស៊ី ទំនងជាមានភាពរំញោចខ្លាំងចំពោះផ្សែងដែលបង្កឡើងដោយការដុតសំរាម។
- ផលប៉ះពាល់លើបរិស្ថាន
  - ផេះ ដែលបក់បំបែកដោយខ្យល់ ឬហូរច្រោះតាមទឹក អាចមានសារធាតុពុលផ្សេងៗ
  - ជាតិពុលផ្សេងៗដែលនៅ ជាប់ជាមួយផេះដែលនៅសេសសល់អាចជ្រាបចូល និងបណ្តាលឲ្យមានជាតិពុលនៅលើផ្ទៃទឹក ឬនៅក្រោមទឹក។



សកម្មភាពនៃការដុតសំរាមរបស់ប្រជាពលរដ្ឋ

### ១.៤.៣.ផលប៉ះពាល់នៃទីលានចាក់សំរាម



ទីលានចាក់សំរាមនៅក្នុងខណ្ឌដង្កោ

ទីលានចាក់សំរាមភាគច្រើននៅប្រទេសកម្ពុជា មានទីតាំងនៅតំបន់ដែលងាយលិចទឹក។ ហេតុនេះអាច បណ្តាលឲ្យមានការបំពុលបរិស្ថាន ព្រោះថានៅក្នុង ដំណើរការនៃការបំបែកសំរាម ឬសំណល់នៅក្នុងទីលាន ចាក់សំរាម ទឹកស្អុយត្រូវបានបង្កើតឡើងដែលអាចធ្វើឲ្យ សារជាតិពុលកើតឡើងនៅក្នុងបរិវេណ ទឹកក្រោមដី និង ដី ស្រែដែលនៅជុំវិញនោះ។ លើសពីនេះទៀត ប្រជា ពលរដ្ឋដែលនៅជុំវិញទីលានចាក់សំរាមទាំងនោះ អាច ប្រឈមទៅនឹងគ្រោះថ្នាក់ដល់សុខភាពដែលបណ្តាល មកពី សត្វរុយ និងសត្វល្អិតដែលប្រកបដោយគ្រោះ ថ្នាក់ផ្សេងទៀត។ តាមការសិក្សាស្រាវជ្រាវទូទៅមួយ ស្តីពី " *ផលប៉ះពាល់សុខភាពទៅលើប្រជាជនដែលរស់នៅជិតទីលានចាក់សំរាមប្រកបដោយគ្រោះថ្នាក់ ការពិនិត្យលើការសិក្សាជម្ងឺរាតត្បាត* " បានសន្និដ្ឋានថា មានការកើនឡើងហានិភ័យនៃផលប៉ះពាល់ដល់សុខភាព (ដូចជា អត្រាកំណើតទាប ពិការភាពពីកំណើត មានការកើតឡើងនូវប្រភេទជម្ងឺមហារីកមួយចំនួន) ត្រូវបានរាយការណ៍ចំពោះប្រជាជនដែលតាំងទីលំនៅជិតទីលានចាក់សំរាមទាំងនោះ។ យ៉ាងណាមិញ ការសិក្សានេះបានទទួលស្គាល់ថា ហានិភ័យទៅលើសុខភាពដែលបណ្តាលមកពីទីលានចាក់សំរាមទាំងនោះ មានការលំបាកក្នុងការកំណត់វិសាលភាពនៃហានិភ័យនេះ។ ករណីនេះបណ្តាលមកពី កង្វះខាតព័ត៌មានពាក់ព័ន្ធទៅនឹងឥទ្ធិពលនៃផលប៉ះពាល់បរិស្ថានកម្រិតទាបទៅលើប្រជាជនទូទៅ។

# ជំពូកទី២
# ការគ្រប់គ្រងកាកសំណល់រឹង

## ២.១.ប្រភេទនិងបញ្ហានៃកាកសំណល់

កាកសំណល់ គឺជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់យើង។ ផ្ទះនីមួយៗនៅក្នុងប្រទេសកម្ពុជាបានបង្កើតសំណល់មួយចំនួន។ វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីសមាសធាតុកាកសំណល់ និងបរិមាណកាកសំណល់ដែលយើងបានបង្កើត ប្រសិនបើយើងចង់បានប្រព័ន្ធគ្រប់គ្រងកាកសំណល់មួយដែលប្រកបដោយប្រសិទ្ធិភាពពិតប្រាកដ។ ផ្នែកនេះមានគោលបំណងពិពណ៌នាអំពីប្រភេទកាកសំណល់ផ្សេងៗគ្នាដែលបានបង្កើត បញ្ហាជាច្រើនដែលវាបង្កឡើងនិង ការផ្ដល់យោបល់មួយចំនួនអំពីរបៀបដោះស្រាយប្រភេទកាកសំណល់នីមួយៗ។

សមាសធាតុកាកសំណល់នៅក្នុងរាជធានីភ្នំពេញមានភាពខុសៗគ្នា ប៉ុន្តែជាមធ្យមជាង ៨០ ភាគរយ បញ្ចូញមកពី ៣ប្រភពៈ សរីរាង្គ ប្លាស្ទិក និងក្រដាស។




### ២.១.១.កាកសំណល់សរីរាង្គ និង កាកសំណល់ប្លាស្ទិក

កាកសំណល់សរីរាង្គមានជាងពាក់កណ្ដាល់នៃកាកសំណល់ដែលយើងបានបង្កើតជារៀងរាល់ថ្ងៃតាមរយៈ ការចម្អិនអាហារ ដែលផ្ដល់ឱកាសក្នុងការបង្កើតកាកសំណល់សរីរាង្គ។ កាកសំណល់សរីរាង្គ គឺជាវត្ថុធាតុដែលបានមកពីរុក្ខជាតិ និងសត្វ រួមមានផ្លែឈើ បន្លែ សាច់ និងកាកសំណល់សួនច្បាររបស់យើង។ នៅពេល

កាកសំណល់សរីរាង្គកើនឡើងកាន់តែច្រើននៅទីលានចាក់សំរាម បង្កើតបានជាឧស្ម័នផ្ទះកញ្ចក់ ហើយធ្វើឲ្យមានការប្រែប្រួលអាកាសធាតុ។ កាកសំណល់សរីរាង្គដែលមិនត្រូវបានទុកដាក់ឲ្យបានត្រឹមត្រូវវាបង្កឲ្យមានបញ្ហានៅក្នុងសហគមន៍។ សត្វល្អិតដែលងាយចម្លងជម្ងឺ និងក្លិនអាក្រក់នៃកាកសំណល់សរីរាង្គធ្វើឲ្យប៉ះពាល់ដល់សុខភាព។

មានវិធីជាច្រើនក្នុងការដោះស្រាយកាកសំណល់សរីរាង្គនៅតាមផ្ទះ ឬសហគមន៍។ វាអាចយកទៅធ្វើជាជីកំប៉ុស ជាជីធម្មជាតិដែលមានជីជាតិខ្ពស់សម្រាប់សួនច្បារ ឬអាចទាញយកឧស្ម័នមេតានពីជីកំប៉ុស ដើម្បីបង្កើតជាឡជីវឧស្ម័ន។ ប្រសិនបើជម្រើសទាំងនេះមិនអាចធ្វើទៅបាន នោះកាកសំណល់សរីរាង្គគួរតែត្រូវបានប្រមូល និងរៀបចំទុកដាក់ឲ្យបានត្រឹមត្រូវដោយមានការប្រមូលពីក្រុមហ៊ុនគ្រប់គ្រងកាកសំណល់។

កាកសំណល់ប្លាស្ទិកជាប្រភពនៃកាកសំណល់ធំនៅក្នុងពិភពលោក ហើយកាកសំណល់ទាំងនេះពិបាកក្នុងការជៀសវាងបាន។ កាកសំណល់នោះមានដូចជា ដបទឹក កែវកាហ្វេ តុក្កតា ថង់នៅផ្សារ និងប្រអប់វេចខ្ចប់អាហាររបស់យើង។ ប្លាស្ទិក មិនមែនកើតឡើងដោយធម្មជាតិនៅក្នុងពិភពលោកនោះទេ ហើយប្រទេសកម្ពុជាត្រូវបានយកវាមកប្រើប្រាស់ក្នុងពេលថ្មីៗ។ ប្លាស្ទិកអាចចំណាយពេលរាប់រយឆ្នាំក្នុងការរលាយមានន័យថា រាល់



បំណែកនៃប្លាស្ទិកដែលត្រូវបានបង្កើតឡើងគឺនៅតែមាន។ ទីលានចាក់សំរាម និងសហគមន៍របស់យើងកំពុងតែមានទៅដោយកាកសំណល់ប្លាស្ទិក។ ប្លាស្ទិកទាំងនេះអាចធ្វើឲ្យស្ទះផ្លូវទឹកដែលបណ្តាលឲ្យមានទឹកជំនន់។ ប្លាស្ទិកក៏ អាចនាំឲ្យស្លាប់ដល់ជីវិតសត្វសមុទ្រដោយសារតែសត្វទាំងនោះបានស៊ីវា ឬដោយសារពួកវាជាប់នៅក្នុងកញ្ចប់ប្លាស្ទិក។ ថ្មីៗនេះអ្នកវិទ្យាសាស្ត្របានរកឃើញថាមីក្រូប្លាស្ទិក( បំណែកប្លាស្ទិកតូចៗ) មាននៅក្នុងត្រីដែលបានទទួលទាននោះវាបានចូលទៅក្នុងខ្លួនរបស់យើង។ ជាចុងក្រោយប្លាស្ទិកអាចនឹងក្លាយទៅជាបញ្ហានៅក្នុងសហគមន៍ពីព្រោះវាងាយកើតមានឡើង។

ដោយសារតែជាតិប្លាស្ទិកមិនងាយរលាយ ដំណោះស្រាយដ៏ល្អបំផុត គឺត្រូវព្យាយាម និងកាត់បន្ថយការប្រើប្រាស់បរិមាណប្លាស្ទិកជារៀងរាល់ថ្ងៃ។ ប្រភេទប្លាស្ទិកមួយចំនួនអាចត្រូវបានប្រមូល និងយកទៅធ្វើការកែច្នៃឡើងវិញ។ ត្រូវព្យាយាមប្រមូលដបទឹក និងវត្ថុស្រដៀងគ្នាផ្សេងទៀតសម្រាប់លក់ទៅអ្នកប្រមូលទិញ។ ប្លាស្ទិកដែលពិបាកយកទៅកែច្នៃឡើងវិញដូចជាប្លាស្ទិក និងប្រអប់វេចខ្ចប់អាហារគួរតែជៀសវាង។

## ២.១.២.កាកសំណល់ក្រដាស និងកាកសំណល់វាយនភណ្ឌ

កាកសំណល់ក្រដាសបានមកពីផលិតផលប្រភេទផ្សេងៗគឺប្រអប់ ឬក្រដាសដែលយើងបានទិញមកដូចជាសៀវភៅ និងកាសែត។ យើងខ្លួនឯងបានចូលរួមបង្កើតកាកសំណល់ដោយការយកវិក័យបត្រក្រដាសពីហាងលក់ឥវ៉ាន់ឬធនាគារ។ កាកសំណល់ក្រដាសវាមិនមែនជាបញ្ហាធំនៅក្នុងសហគមន៍ឡើង ដោយសារតែវាងាយរលាយមិនដូចប្លាស្ទីកនោះទេ។ ប៉ុន្តែ ការផលិតក្រដាសបានប្រើប្រាស់ធនធានជាច្រើន ដូចជាដើមឈើ និងទឹកដែលអាចបង្កឲ្យអន្តរាយដល់បរិស្ថាន។ ក្រដាសគួរតែបោះចោលឲ្យបានត្រឹមត្រូវ ឬគួរជៀសវាងប្រើប្រាស់ប្រសិនបើអាច។





សម្លៀកបំពាក់ដែលយើងឈប់ប្រើប្រាស់ ហើយបានបោះចោលនោះហៅថាជាកាកសំណល់វាយនភណ្ឌ។ បើទោះបីជាកាកសំណល់វាយនភណ្ឌមិនត្រូវបានបញ្ចេញពីតាមផ្ទះនៅក្នុងរាជធានីភ្នំពេញមានចំនួនច្រើនក៏ដោយ ប៉ុន្តែកាកសំណល់ទាំងនេះបានកើតមាននៅឯទីលានចាក់សំរាម ហើយវាអាចបង្កើតទៅជាឧស្ម័នមេតាន។ ពិតជាសំខាន់ណាស់ ក្នុងការព្យាយាម និងរកវិធីប្រើប្រាស់សម្លៀកបំពាក់ចាស់ៗដែលយើងឈប់ប្រើប្រាស់ដូចជាយកទៅធ្វើជាក្រណាត់ជូត សម្អាតផ្ទះ។

## ២.១.៣.កាកសំណល់ កែវ និងកាកសំណល់លោហៈធាតុ

កាកសំណល់ កែវបានមកពីដបភេសជ្ជៈ ផ្សេងៗដែលយើងបានទិញ ប៉ុន្តែក៏អាចបានមកពីសម្ភារៈ ភេសជ្ជៈផ្សេងៗទៀតដែលដាក់អាហារ ឬផលិតផលថែសម្ផស្សផ្សេងៗ។ នៅរាជធានីភ្នំពេញពុំមានការកែច្នៃឡើងវិញជាផ្លូវការឡើយលើកាកសំណល់កែវ មានន័យថា កាកសំណល់ កែវ ស្ទើរតែទាំងអស់ដែលយើងបានទិញ ត្រូវបានបោះចោលនៅទីលានចាក់សំរាម ឬនៅក្នុងសហគមន៍របស់យើង។ នៅតាមមូលដ្ឋានអំបែងកែវនៅតាមផ្លូវ និងខ្សែទឹកអាចបង្កឲ្យមានរបួស និងគ្រោះថ្នាក់ដល់កុមារ។

កំប៉ុងភេសជ្ជៈដែលមានជាតិអាលុយមីញ៉ូម គឺជាប្រភពដ៏ធំមួយក្នុងការបង្កើតកាកសំណល់លោហៈធាតុ ប៉ុន្តែកាកសំណល់លោហៈនេះក៏អាចកើតមកពីសម្ភារៈ សំណង់ដូចជា ដែកគោល និងវីស ឬខ្ចៅ(មួល)។ លោហៈគឺជាកាកសំណល់ដែលមានតម្លៃ ហើយអ្នកប្រមូលទិញក្នុងមូលដ្ឋានគេនឹងមកទិញ ឬមកយកដល់ទីកន្លែងសហគមន៍របស់អ្នក។ គួរតែប្រមូល ហើយទុកលក់ ឬប្រគល់ជូនគេដើម្បីគេយកទៅកែច្នៃឡើងវិញដោយមិនត្រូវបោះចោលនៅតាមផ្លូវ ឬគំនរសំរាម។

### ២.១.៤.កាកសំណល់ អេឡិចត្រូនិច



កាកសំណល់ដែលក្រៅពីប្រភេទកាកសំណល់ខាងលើ មានប្រហែលជា ១០%នៃសំណល់ទាំងអស់នៅរាជធានីភ្នំពេញ។ ប្រភេទកាកសំណល់ដែលកើនឡើងឆាប់រហ័សបំផុតនៅក្នុងប្រទេសកម្ពុជា គឺប្រភេទកាកសំណល់អេឡិចត្រូនិចដែលគេហៅថា អ៊ីវេស ( e-waste) ។ កាកសំណល់នេះបានមកពីផលិតផល ដូចជា ទូរស័ព្ទ កុំព្យូទ័រ និងកាមេរ៉ា។ នៅពេលណាកាកសំណល់អេឡិចត្រូនិចត្រូវបានចោលនៅគំនរសំរាម ក្នុងទន្លេ និងក្នុងសហគមន៍ សារធាតុគីមីដែលគ្រោះថ្នាក់អាចជ្រាបចេញមក ហើយវាអាចបង្កទៅជាបំពុលទឹក និងដី។ នៅពេលកាកសំណល់ទាំងនេះឆេះនោះវានឹងបំភាយចេញនូវឧស្ម័នគ្រោះថ្នាក់។ ពិតជាសំខាន់ណាស់ ក្នុងការព្យាយាម និងប្រើប្រាស់គ្រឿងអេឡិចត្រូនិចឲ្យអស់លទ្ធភាពដែលអាចធ្វើទៅបាន ហើយនៅពេលដែលមវាមិនអាចប្រើការបាន គួរតែបោះចោលដោយមានការទទួលខុសត្រូវ ឬក៏អាចលក់ ឬឲ្យទៅអ្នកកែច្នៃឡើងវិញនៅក្នុងមូលដ្ឋាន។

## ២.២.ការគ្រប់គ្រងកាកសំណល់រឹង

### ២.២.១.នៅក្នុងរាជធានីភ្នំពេញ និងនៅតំបន់ជាយក្រុង

រាជធានីភ្នំពេញមានការរីកចម្រើន និងការអភិវឌ្ឍន៍យ៉ាងខ្លាំងនៅក្នុង២ទសវត្សរ៍ចុងក្រោយនេះ។ អគារខ្ពស់ៗទំនើបៗបានកែប្រែទេសភាពរាជធានីភ្នំពេញ និងផ្លូវដែលធ្លាប់តែពោរពេញដោយកង់ និងរឺម៉ក់កង់បី ឥឡូវនេះមានពោរពេញទៅដោយម៉ូតូ និងរថយន្តជាច្រើន។ ការកើនឡើងនៃការប្រើប្រាស់ និងការកើនឡើងនៃកាកសំណល់បានដើរទៅព្រមជាមួយគ្នានិងការអភិវឌ្ឍន៍ហើយប្រទេសកម្ពុជាមានភាពយឺតយ៉ាវក្នុងការដោះស្រាយការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងរាជធានី។ សមាគមន៍ជាច្រើននៅតែមិនទាន់មានការគ្រប់គ្រងកាកសំណល់ ហើយផ្លូវនិងផ្លូវទឹកនៅតែបន្តមានការចោលសំរាម និងមានជាតិពុល។ មានវិធីសាស្ត្រជាច្រើនអ្នកដឹកនាំសហ

គមន៍អាចប្រើប្រាស់បានសម្រាប់ការស៊ូមតិ ឬគាំទ្រមតិក្នុងការដោះស្រាយការគ្រប់គ្រងកាកសំណល់ និងធ្វើការជាមួយក្រុមហ៊ុនគ្រប់គ្រងសំរាមក្នុងស្រុក។

បើទោះជាដំណោះស្រាយនៃការគ្រប់គ្រងកាកសំណល់ជាច្រើនត្រូវការ ការគាំទ្រពីរដ្ឋាភិបាល និងឧស្សាហកម្មក៏ដោយតែមានកត្តាជាច្រើនដែលយើងអាចធ្វើបាននៅសហគមន៍ដើម្បីគ្រប់គ្រងកាកសំណល់។ យុទ្ធសាស្ត្រទាំងនេះភាគច្រើនត្រូវបានគេស្គាល់ថា ទស្សនទាន«បីអា (3A) » គឺកាត់បន្ថយប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ។

### ២.២.២.បញ្ហាប្រឈម និង ដំណោះស្រាយ

ទោះបីជាបញ្ហាប្រឈមជាច្រើនកំពុងកើតមានឡើងក្នុងសហគមន៍ក្រីក្រនៅរាជធានីភ្នំពេញក៏ដោយ មានជំហានជាច្រើនដែលសមាជិកសហគមន៍អាចយកទៅអនុវត្តដើម្បីដោះស្រាយឬកាត់បន្ថយនូវបញ្ហាប្រឈមទាំងនោះបាន។

- សហគមន៍របស់អ្នកពុំទាន់ទទួលបានសេវានៃការគ្រប់គ្រងកាកសំណល់ក្នុងរាជធានីភ្នំពេញ
  - តំណាងអាជ្ញាធរក្នុងមូលដ្ឋានត្រូវរៀបចំកិច្ចប្រជុំជាមួយក្រុមហ៊ុនប្រមូលសំរាម ដើម្បីទីតាំងប្រមូលសំរាមនៅក្នុងសហគមន៍
  - ស្នើក្រុមហ៊ុនប្រមូលសំរាម ខណ្ឌ ឬសង្កាត់ ឲ្យផ្តល់ធុងសំរាមធំ ឬធុងសម្រាប់ផ្ទុកសំរាម។
- ក្រុមហ៊ុនប្រមូលសំរាមបានមកដល់ទីតាំងប្រមូលសំរាមសហគមន៍ប៉ុន្តែប្រមូលសំរាមមិនអស់
  - ទុកដាក់សំរាមឲ្យមានរបៀប ទាំងនៅក្នុងធុង ឬក្នុងថង់ដោយចង និងបិទឲ្យជិត
  - អាជ្ញាធរមូលដ្ឋានត្រូវទាក់ទងទៅតំណាងក្រុមហ៊ុនប្រមូលសំរាមដើម្បីសួរពីមូលហេតុដែលពួកគេមិនប្រមូលសំរាមឲ្យអស់។
- អ្នកបើកបរឡានដឹកសំរាម មកប្រមូលសំរាមមិនទៀងទាត់ដែលបង្កជាការលំបាកក្នុងការទុកដាក់សំរាម
  - សង្កាត់ ឬខណ្ឌក្នុងមូលដ្ឋាន ត្រូវមានវិធានការរៀបចំកន្លែង ប្រមូលសំរាមឲ្យនៅជិត ឬមានកាលវិភាគឲ្យត្រឹមត្រូវជាមួយក្រុមហ៊ុន
  - ប្រសិនបើមានកាលវិភាគ ត្រូវទាក់ទងទៅខាងក្រុមហ៊ុនដើម្បីសួរនាំពួកគេតាមដានរឿងនេះ
  - ប្រសិនបើគ្មានកាលវិភាគ ត្រូវទាក់ទងទៅខាងក្រុមហ៊ុនដើម្បីឲ្យពួកគេផ្តល់នូវកាលវិភាគច្បាស់លាស់មួយ។
- ទីតាំងប្រមូលសំរាមស្ថិតនៅលើដីរបស់បុគ្គលណាម្នាក់ហើយគេពុំអនុញ្ញាតឲ្យអ្នកដទៃដាក់សំរាម
  - បង្កើតជាជម្រើសនៃទីតាំងប្រមូលសំរាម
  - រកបុគ្គលក្រុមហ៊ុនដែលមានរទេះសំរាមរុញឲ្យប្រមូលកាកសំណល់នៅក្នុងសហគមន៍ទាំងមូល

- ស្នើឲ្យក្រុមហ៊ុន ឬក្រុងផ្សេងទៀតដើម្បីឧបត្ថម្ភធុងសំរាមធំៗដើម្បីធ្វើឲ្យទីតាំងប្រមូលសំរាមនូវមានការរំខានតិចតួចដល់ម្ចាស់ដី។

➢ ទីតាំងប្រមូលសំរាមនៅឆ្ងាយ

- រកបុគ្គលក្រុមហ៊ុនដែលមានរទេះសំរាមរុញឲ្យប្រមូលកាកសំណល់នៅក្នុងសហគមន៍ទាំងមូល
- លើកទឹកចិត្តសមាជិកសហគមន៍ឲ្យទុកដាក់កាកសំណល់ឲ្យមានរបៀប និងត្រូវយកវាទៅដាក់ទីតាំងប្រមូលសំរាម
- ការបង្កើតក្រុមប្រមូលសំរាមពីសហគមន៍ ឬជួលអ្នកណាម្នាក់ក្នុងសហគមន៍ឲ្យប្រមូលសំរាម។

➢ ក្រុមហ៊ុនប្រមូលសំរាមមិនឆ្លើយតបទៅនឹងសំណើរបស់សហគមន៍

- សង្កាត់ឬ ខណ្ឌត្រូវព្យាយាមរកវិធីទំនាក់ទំនងឲ្យបានច្រើន រួមមានតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ហ្វេសប៊ុក អ៊ីមែល ទូរស័ព្ទ និងទៅកាន់ការិយាល័យផ្ទាល់នៅក្នុងសហគមន៍
- ទាក់ទងទៅសាលាក្រុង ឬអង្គការក្នុងស្រុកដែលធ្វើ ការនៅក្នុងសហគមន៍របស់អ្នកដើម្បីជួយអ្នក។

## បញ្ហាប្រឈម និងដំណោះស្រាយនៅតំបន់ជាយក្រុង

❖ *កាកសំណល់កាន់តែតិច បញ្ហាកាន់តែតិច* : ការកាត់បន្ថយគឺជាវិធីមួយដ៏មានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងកាកសំណល់។ ប្រសិនបើអ្នកកាត់បន្ថយបរិមាណនៃកាកសំណល់នៅក្នុងសហគមន៍ ពេលនោះនឹងមានតិចតួចហើយងាយស្រួលក្នុងការគ្រប់គ្រង។

❖ *យកថង់ដែលអាចប្រើប្រាស់បានឡើងវិញនៅពេលទៅផ្សារទិញទំនិញ* : នៅពេលទៅផ្សារជាធម្មតាប្រើប្រាស់ថង់ប្លាស្ទិកលើសពី ៥ថង់។ ជារឿយៗយើងបានបោះចោលថង់ប្លាស្ទិកនោះភ្លាមៗនៅពេលដែលយើងទៅដល់ផ្ទះ។ ប្រសិនបើមនុស្សគ្រប់គ្នាយកថង់ផ្ទាល់ខ្លួនទៅផ្សារយើងអាចកាត់បន្ថយបរិមាណនៃប្រភេទកាកសំណល់ដែលពិបាកគ្រប់គ្រងនេះ។

❖ *ប្រើប្រាស់ប្រអប់ម្ហូបអាហារ និង ស្លាបព្រាសមដែលអាចប្រើប្រាស់ឡើងវិញ* : ប្រអប់ដាក់ម្ហូបអាហារប្រភេទ ស្ទីរ៉ូហ្វម (Styrofoam) និងកែវខ្ចប់កាហ្វេក្តៅមិនអាចយកទៅកែច្នៃឡើងវិញបានទេនៅកម្ពុជា។ ប្រសិនបើអ្នកប្រើប្រាស់ប្រភេទប្រអប់ទាំងនេះជាប្រចាំ សូមយកប្រអប់ដែលអាចប្រើឡើងវិញបានតាមខ្លួនដើម្បីកាត់បន្ថយបរិមាណនៃវត្ថុធាតុដែលលំបាកក្នុងការកែច្នៃឡើងវិញនេះ។

❖ *ប្រើប្រាស់ដបទឹក និងថូធំៗ ឬតម្រងទឹកដែលអាចប្រើប្រាស់ឡើងវិញ* : យើងទាំងអស់គ្នាសុទ្ធតែត្រូវការទឹកដើម្បីរស់ ប៉ុន្តែការទិញទឹកដបប្លាស្ទិកជារៀងរាល់ថ្ងៃអាចបង្កើតជាកាកសំណល់ប្លាស្ទិកបានយ៉ាងលឿន។ តម្លៃនៃដបទឹកដែលអាចប្រើប្រាស់ឡើងវិញអាចទូទាត់តម្លៃនៃចំនួនប្លាស្ទិកក្នុងរយៈពេល ពីរឬបីសប្តាហ៍។ ប៉ុន្តែតម្លៃនៃថូទឹកធំៗ ឬតម្រងទឹកអាចចែករំលែកជាមួយអ្នកជិតខាងបាន។ អ្នកអាចប្រើ

ប្រាស់ឡើងវិញនូវដបទឹកដែលសម្រាប់ប្រើបានតែម្តងផងដែរតែត្រូវចាំថា ដបត្រូវលាងសម្អាតឲ្យបានញឹកញាប់ដើម្បីការពារកុំឲ្យកើតមានបាក់តេរី។

- *គិតគូរអំពីការជំនួសសម្ភារខ្ចប់ម្ហូបអាហារ* : បច្ចុប្បន្ននេះអាជីវកម្មជាច្រើនបានលក់ប្រអប់ខ្ចប់ម្ហូបអាហារ ចាន និងស្លាបព្រា សម ដែលងាយរលួយ និងរលាយ។ របស់ទាំងនេះប្រើប្រាស់ដូចគ្នាទៅនឹងផលិតផលដែលអ្នកធ្លាប់ប្រើ ប៉ុន្តែមិនបង្កអន្តរាយដល់ភពផែនដី និងងាយស្រួលក្នុងការគ្រប់គ្រង។ នេះមានន័យថា អ្នកមិនធ្លាប់ប្តូររបៀបរស់នៅរបស់អ្នកឡើយ។ ថ្ងៃក្រោយពេលដែលអ្នកទិញម្ហូបអាហារខ្ចប់ ចូរចែករំលែកព័ត៌មាននេះជាមួយអ្នកលក់ ហើយមើលថាតើពួកគេចាប់អារម្មណ៍ក្នុងការផ្លាស់ប្តូរដែរ ឬទេ។
- ជ្រើសរើសដើម្បីប្រើប្រាស់ឡើងវិញ

សម្ភារជាច្រើនដែលយើងប្រើប្រាស់ត្រូវបានបោះចោលក្រោយពីការប្រើប្រាស់តែមួយដង។ ការប្រើប្រាស់ផលិតផលឡើងវិញមានសារសំខាន់ណាស់ បើទោះបីជាមិនអាចប្រើប្រាស់ផលិតផលក្នុងគោលបំណងដើមបានក៏ដោយ ក៏នៅតែមានវិធីជាច្រើនដែលយើងអាចបង្កើតគុណភាពតម្លៃពីផលិតផលចាស់ៗ។ ដំណើរការនៃការផ្លាស់ប្តូរផលិតផលទៅជាអ្វីដែលថ្មី និងតម្លៃខ្ពស់ត្រូវបានគេហៅថា ការកែច្នៃឡើងវិញប្រកបដោយភាពច្នៃប្រឌិត។

- ការធ្វើជីកំប៉ុស

ជាមួយនឹងភាគរយដ៏ច្រើននៃកាកសំណល់ដែលបញ្ចេញពីតាមផ្ទះដែលមានប្រភពមកពីសម្ភារសរីរាង្គ បង្ហាញថា វិធីសាស្រ្តក្នុងការប្រើប្រាស់ឡើងវិញនូវសម្ភារសរីរាង្គទាំងនោះមានសារសំខាន់ណាស់។ ការធ្វើជីកំប៉ុស គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្វែរកាកសំណល់ផ្ទះបាយ និងសម្ភារសរីរាង្គផ្សេងៗ ដូចជា ស្លឹកឈើឲ្យទៅជាជីកំប៉ុសដែលអាចប្រើបានអាចលក់ ឬប្រើសម្រាប់ធ្វើ កសិកម្ម និងសួនច្បារ។ ការធ្វើជីកំប៉ុសអាចធ្វើបានទាំងនៅតាមគ្រួសារ ឬសហគមន៍។ ការធ្វើជីកំប៉ុសមានផ្នែកមិនល្អរួមមានការចំណាយនៃការចាប់ផ្តើមដំណើរការជះ ក្លិនស្អុយនៅជិតផ្ទះរបស់អ្នក និងបន្ទុកការងារបន្ថែមក្នុងការរក្សាវា។ មានការណែនាំសំខាន់មួយចំនួនអាចត្រូវបានផ្តល់ជូនប្រសិនបើ អ្នកចាប់អារម្មណ៍ក្នុងការចាប់ផ្តើមធ្វើជីកំប៉ុសដោយ ខ្លួនឯង។



ជីកំប៉ុស

❖ ឡជីវឧស្ម័ន

ឡជីវឧស្ម័នស្រដៀងទៅនឹងជីកំប៉ុសត្រង់ថា គេប្រែកាកសំណល់សរីរាង្គដើម្បីផលិត។ ជំនួសឲ្យជីកំប៉ុសសម្រាប់ធ្វើជាជីរុក្ខជាតិ ឡជីវឧស្ម័នបង្កើតជីវឧស្ម័នដែលអាចផលិតថាមពលក្នុងផ្ទះ ដូចជាចង្ក្រានឡវ។ ផ្ទះមួយមិនមានកាកសំណល់សរីរាង្គគ្រប់គ្រាន់ដើម្បីបង្កើតបរិមាណជីវឧស្ម័នដែលមានប្រយោជន៍ទេ ដូច្នេះវាមានទំហំកាកសំណល់ច្រើនដើម្បីបង្កើតជីវឧស្ម័ន។ ឡជីវឧស្ម័នត្រូវការចំណាយខ្ពស់ជាងការធ្វើជីកំប៉ុសក្នុងការចាប់ផ្តើមដំណើរការ។



ការធ្វើឡជីវឧស្ម័នរបស់ប្រជាពលរដ្ឋនៅស្រុកព្រៃឈរ ខេត្តកំពង់ចាម

❖ ធុងសំរាមធ្វើពីដបទឹកប្លាស្ទិក

ដើម្បីគ្រប់គ្រងកាកសំណល់ឲ្យបានត្រឹមត្រូវ គួរតែមានកន្លែងសម្រាប់រក្សាវាទុកមុននឹងត្រូវបានប្រមូលដោយក្រុមហ៊ុនគ្រប់គ្រងកាកសំណល់ក្នុងរាជធានី។ ធុងសំរាមធំៗអាចមានតម្លៃថ្លៃ និងមិនមានលទ្ធភាពទិញមកប្រើប្រាស់។ មានបច្ចេកទេសប្រើប្រាស់ដបប្លាស្ទិកដើម្បីបង្កើតជាធុងសំរាម ដ៏រឹងមាំមិនជ្រាបទឹក និងមានប្រសិទ្ធិភាពសម្រាប់ប្រើប្រាស់ នៅតាមផ្ទះឬសហគមន៍។ ធុងសំរាមទាំងនេះអាចជួយញែកប្រភេទកាកសំណល់ផ្សេងៗគ្នា ឬការពារកុំឲ្យចោលកាកសំណល់រាយប៉ាយនៅលើដី។




ធុងសំរាមធ្វើពីដបទឹកសុទ្ធ

អ្វីៗទាំងអស់សុទ្ធតែមានតម្លៃ ជំហានដំបូងគួរតែកាត់បន្ថយ និងប្រើប្រាស់ម្តងទៀត ប៉ុន្តែប្រសិនបើវាមិនអាចទៅរួចអ្នកគួរព្យាយាមហើយនិងកែច្នៃឡើងវិញមុនពេលបោះចោលផលិតផលនោះ។ វត្ថុនីមួយៗដែលយើងបានចោលទៅគំនរសំរាមខ្លះមានតម្លៃចំពោះអ្នកដែលត្រូវការ។ លំបាកណាស់ក្នុងការស្វែងរកអ្នកដែលត្រូវការវត្ថុដែលអ្នកលែងប្រើប្រាស់ហើយឲ្យតម្លៃលើរបស់នោះ។ ជាទូទៅមានវត្ថុបីយ៉ាងដែលអ្នករើសសំរាមក្នុងតំបន់តែងតែប្រមូលយករួមមាន ដបប្លាស្ទីក កំប៉ុងអាលុយមីញ៉ូម និងប្រអប់ក្រដាសកាតុង។ ការកែច្នៃឡើងវិញរួមមាន៖

- រក្សាទុកដាក់វត្ថុទាំងអស់ឲ្យមានរបៀបរៀបរយ។ ការរៀបចំទុកដាក់ឲ្យរបៀបងាយស្រួលក្នុងការលក់ ទៅឲ្យអ្នកប្រមូលសំរាមដែលអាចកែច្នៃបានតាមមូលដ្ឋាន
- ត្រូវបង្កើតទីតាំងប្រមូលកាកសំណល់ក្នុងសហគមន៍។ ប្រសិនបើមិនមានអ្នកប្រមូលទិញសំរាមដែលអាចកែច្នៃបាន ប្រមូលថង់ប្លាស្ទីក និងអាលុយមីញ៉ូមដែលអាចកែច្នៃបានទាំងអស់ទៅទុកជាគំនរធំមួយនោះវានឹងទាក់ទាញឲ្យពួកគេចូលមកទិញ
- សម្អាតដបរបស់អ្នកមុននឹងបោះចោលដូច្នេះវាអាចឲ្យគេរើសទុកដោយគេមិនបោះចោលបន្ត
- រក្សាទុកផលិតផលពីក្រដាសឲ្យស្ងួត
- ប្រសិនបើអ្នកប្រមូលសំរាមដែលអាចកែច្នៃបាននៅក្នុងសហគមន៍របស់អ្នកមិនប្រមូលប្រភេទសំរាមជាក់លាក់ណាមួយចូរព្យាយាមមើល ថាតើមានអ្នកដទៃទៀតដែលនៅក្បែរនោះប្រមូលវាដែរ ឬទេ។

ដំណោះស្រាយគ្រប់គ្រងកាកសំណល់កាន់តែងាយស្រួលនៅពេលណាកាកសំណល់ត្រូវបានញែក និងរក្សាទុកក្នុងថង់ឬ ប្រអប់ឲ្យបានត្រឹមត្រូវ។ សហគមន៍ខុសៗគ្នាអាចជ្រើសរើសការញែកកាកសំណល់របស់ពួកគេតាមវិធីផ្សេងៗអាស្រ័យលើដំណោះស្រាយដែលពួកគេបានបង្កើត។

➢ ការញែកសំណល់នៅតាមលំនៅដ្ឋាន

  ▪ ញែកសំណល់ដែលប្រកបដោយគ្រោះថ្នាក់ចេញពីសំណល់ដែលមិនគ្រោះថ្នាក់។ ទោះបីជានៅតាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋមិនមែនជាប្រភពចំបងដែលបង្កើតឡើងនូវសំណល់គ្រោះថ្នាក់ក៏ដោយ ក៏ប៉ុន្តែវត្ថុមួយចំនួនដូចជាថ្មពិល អាគុយ កំប៉ុងថ្នាំសម្លាប់សត្វ និងកំប៉ុងដែលមានសារធាតុគីមីមួយចំនួនទៀតមានផ្ទុកនូវសារធាតុពុល ដូច្នេះសំណល់វត្ថុទាំងនោះគួរតែញែកចេញពីសំណល់ធម្មតា។ លើសពីនេះទៅទៀតសំណល់ ធម្មតាអាចយកទៅប្រើក្នុងគោលបំណងផ្សេងៗទៀត គួរតែញែកចេញពីសំណល់ដែលត្រូវបោះចោល (ឧ. ដូចជាថង់ប្លាស្ទិក និងកញ្ចប់មួយចំនួនយើងអាចយកទៅលាងសម្អាតដើម្បីទុកប្រើប្រាស់ឡើងវិញ ចៀសវាង ការទិញស្បោងឬប្រអប់មកទុកប្រើប្រាស់)។
  ▪ ការញែកសំណល់សម្រាប់កែច្នៃ ៖ ការញែកសំណល់រឹងដូចជា ក្រដាស កំប៉ុងអាលុយមីញ៉ូម អំបែង ដប ឬកែវ និងសារធាតុប្លាស្ទិកចេញពីគ្នានៅឯ ប្រភពបង្កើតសំណល់រឹង ដើម្បីយកទៅកែច្នៃ គឺជាមធ្យោបាយដ៏ល្អប្រសើរមួយ ដើម្បីសន្សំសំចៃវត្ថុធាតុដើម គឺមានន័យថាយើងអាចកាត់

បន្ថយការទាញយកធនធានធម្មជាតិយកមកប្រើប្រាស់។ ទន្ទឹមនឹងការញែកសំណល់ទាំងនេះ បញ្ហាដែលយើងត្រូវគិតគូរគឺថាតើយើងត្រូវទុកដាក់ វាបែបណាមុនពេលដែលសេវាកម្មនៃការប្រមូលសំរាមមកដល់។ នៅតាមបណ្តាប្រទេសមួយចំនួនដែលមានប្រព័ន្ធកែច្នៃល្អប្រសើររួមផ្សំនឹងមានគោលការណ៍ណែនាំ និងការអប់រំស្តីពីការទុកដាក់ ឬបោះចោលសំណល់រឹង ប្រជាជនរបស់គេបានយកសំណល់ដែលគេញែកទៅទុកដាក់តាមគោលការណ៍ដែលរដ្ឋាភិបាលបានណែនាំ។

- ការញែកសំណល់ដែលនៅតាមទីសាធារណៈ រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្ម

ការញែកសំណល់ដែលនៅតាមទីសាធារណៈ រោងចក្រ សហគ្រាស និងអគារពាណិជ្ជកម្ម មានភាពលំបាក និងស្មុគស្មាញជាងតាមលំនៅស្ថាន ដោយទីនោះជាកន្លែងដែលមមាញឹក និងមានទំនាក់ទំនងទៅនឹងប្រជាជនទូទៅ ដូច្នេះការញែកសំណល់នេះវាទាក់ទងទៅនឹងឥរិយាបថ និងការយល់ដឹងរបស់ប្រជាពលរដ្ឋផងដែរ។ នៅបណ្តាប្រទេសមួយចំនួនដូចជាប្រទេសថៃ និងប្រទេសស៊ុយអែត រដ្ឋាភិបាលរបស់គេបានប្រើប្រាស់ធុងដែលមានពណ៌ផ្សេងៗគ្នា ឬធ្វើស្លាកសញ្ញាចំណាំដើម្បីឲ្យអតិថិជន និងប្រជាពលរដ្ឋទូទៅ អាចដឹងបានថាធុងមួយណាសម្រាប់ដាក់ សំណល់លោហៈធាតុ សំណល់ប្លាស្ទិក និងធុងមួយណាសម្រាប់ដាក់សំណល់អាហារ (ឬសំណល់ ដែលអាចបំបែកបានដោយពពួកមីក្រូសារពាង្គកាយ)។ ប៉ុន្តែការគ្រប់គ្រងបែបនោះគឺទាមទារឲ្យមានអប់រំ និងប្រកាសជាព័ត៌មានឲ្យប្រជាពលទូទៅបានយល់ដឹង។

ទីតាំងប្រមូលសំរាមនៅតំបន់ជាយក្រុង : តំបន់ខ្លះមានការពិបាកសម្រាប់ក្រុមហ៊ុនគ្រប់គ្រងកាកសំណល់ក្នុងរាជធានីចូលទៅប្រមូលកាកសំណល់។ ចូរកំណត់ទីតាំងសម្រាប់ប្រមូលកាកសំណល់។ផ្ទះនីមួយៗត្រូវមានការទទួលខុសត្រូវក្នុងការយកកាកសំណល់របស់ពួកគេទៅដាក់នៅទីតាំងនេះ។ ទីតាំងនេះធ្វើឲ្យកាកសំណល់មិនរាយប៉ាយនៅក្នុងសហគមន៍ និងធ្វើឲ្យងាយស្រួលដល់ក្រុមហ៊ុនក្នុងការគ្រប់គ្រងកាកសំណល់ចូលទៅប្រមូល។

- *<u>ជំហានសម្រាប់ការបង្កើតទីតាំងប្រមូលសំរាមក្នុងសហគមន៍</u>*

- រកទីតាំងដែលសមរម្យស្ថិតនៅតាមផ្លូវ ឬជិតផ្លូវដែលរថយន្តប្រមូលសំរាមឆ្លងកាត់
- សហការជាមួយម្ចាស់ដី សង្កាត់ ខណ្ឌ និងក្រុមហ៊ុនប្រមូលសំរាម ដើម្បីកំណត់ទីតាំងប្រមូលសំរាមថ្មីនេះនិងបន្ថែមផ្លូវឆ្លងកាត់របស់ក្រុមហ៊ុនប្រមូលសំរាម
- ជូនដំណឹងដល់សមាជិកសហគមន៍អំពីទីតាំងប្រមូលសំរាមថ្មីនេះ និងពេលវេលាដែលឡានក្រុមហ៊ុនប្រមូលសំរាម ចូលមកប្រមូលសំរាម
- លើកទឹកចិត្តឲ្យសមាជិកសហគមន៍រក្សាទុកសំរាមនៅផ្ទះ និងយកវាទៅទីតាំងប្រមូលសំរាមមុនពេលឡានក្រុមហ៊ុនប្រមូលសំរាមមកដល់។

➢ *គន្លឹះសម្រាប់បង្កើតទីតាំងប្រមូលសំរាមក្នុងសហគមន៍*

- ទីតាំងប្រមូលសំរាមនិងមិនទទួលបានជោគជ័យនោះទេ ប្រសិនបើម្ចាស់ដីមិនគាំទ្រ។ សូមគិតអំពីវិធីណាមួយដែលម្ចាស់ដីអាចទទួលបានសំណងសមរម្យ
- សូមបង្កើតទីតាំងប្រមូលសំរាមនៅជិតនឹងប្រភពទឹក នៅមុខបំពង់បង្ហូរឬក្រោមអគារ
- ធុងសំរាមធំ ឬធុងជិតប៉ុនគ្នាអាចដាក់សំរាមឲ្យមានរបៀបរៀបរយនិងមិនហើរឬបើងចេញ។

# ជំពូកទី៣
# ការគ្រប់គ្រងសំណល់រាវ

## ៣.១.ការគ្រប់គ្រងប្រព័ន្ធបង្ហូរទឹកកខ្វក់

- ទប់ស្កាត់ការរំលោភដីសាធារណៈនៃប្រព័ន្ធលូ ឬការសាងសង់សំណង់ផ្សេងៗដែលធ្វើឲ្យខូចខាតប្រព័ន្ធលូ ឬរាំងស្ទះដល់ចរន្តហូរនៃប្រព័ន្ធលូ
- ទប់ស្កាត់ការរំលោភដីសាធារណៈនៃអាងស្តុកធម្មជាតិ ឬការចាក់លុបអាងស្តុកធម្មជាតិដែលធ្វើឲ្យបាត់បង់សមត្ថភាពស្តុក ឬសម្អាតទឹកកខ្វក់
- សិក្សា និងធ្វើការបង្វែរប្រព័ន្ធលូបញ្ចេញទឹកកខ្វក់ទីប្រជុំជនដែលហូរចូលផ្ទាល់ទៅក្នុងតំបន់ទឹកសាធារណៈ ឲ្យហូរឆ្លងកាត់អាងស្តុកធម្មជាតិ ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ជាមុន
- រៀបចំផែនការ និងជម្រុញការអនុវត្តការស្តារអាងស្តុកធម្មជាតិ ដើម្បីធានាសមត្ថភាពស្តុក និងសម្អាតតាមលក្ខណៈធម្មជាតិនៃទឹកកខ្វក់ទីប្រជុំជន
- ធ្វើការគ្រប់គ្រង និងដំណើរការស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម ដើម្បីធានាគុណភាពទឹកកខ្វក់សម្អាតរួចដែលត្រូវបញ្ចេញ គឺឆ្លើយតបនឹងស្តង់ដារបញ្ចេញទឹកកខ្វក់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី២ នៃអនុក្រឹតលេខ ២៣៥ អនក្រ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធកម្មទឹកកខ្វក់ និងស្តង់ដារនៃការបញ្ចេញទឹកកខ្វក់ដោយឡែកដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

### ៣.១.១.ការគ្រប់គ្រងប្រព័ន្ធលូ

ចំពោះការគ្រប់គ្រងទឹកលូ រាជធានីភ្នំពេញត្រូវបានបែងចែកជាតំបន់ចំនួនបី(ជើងឯក តាម៉ុក និងតំបន់ផ្សេងទៀត) និងលទ្ធភាពនៃការអនុវត្តលើប្រព្រឹត្តិកម្មនៅនិងកន្លែងនិងក្រៅកន្លែងសម្រាប់ឆ្នាំគោលដៅ២០៣៥ ត្រូវបានវាយតម្លៃជាវិធានការសំណង់។ ជាលទ្ធផលប្រព្រឹត្តិកម្មក្រៅកន្លែងត្រូវបានអនុវត្តឡើងលើតំបន់ប្រព្រឹត្តិកម្មជើងឯក និងរោងចក្រប្រព្រឹត្តិកម្មសំណង់រឹង (STP) ដែលបានប្រើប្រាស់ដំណើរការកាកសំណល់រឹងទំនើប (CASP) ត្រូវបានស្នើសុំឡើង។ ម្យ៉ាងវិញទៀត ប្រព្រឹត្តិកម្មនៅកន្លែងដែលណែនាំ Johkasou ត្រូវបានស្នើឡើងក្នុងប្រព្រឹត្តិកម្មតាម៉ុក។ ក្នុងតំបន់ផ្សេង ការសាងសង់អាងទទួលទឹកលូដែលជាឧបករណ៍មានអនាម័យបំផុតនៅPPCC ត្រូវបានផ្តល់អនុសាសន៍ជាពិសេសក្នុងគ្រួសារដែលបង្គន់អនាម័យឬបង្គន់ដីកមិនត្រូវបានបំពាក់ ហើយការណែនាំនៃប្រព័ន្ធទឹកកង្វក់ខ្ពស់ដូចជាJohkasou ត្រូវបានផ្តល់អនុសាសន៍នៅក្រោយឆ្នាំគោលដៅ។ ដោយសារតែមានការខ្វះខាតបទប្បញ្ញត្តិស្ថាប័ននិងតាមផ្លូវច្បាប់ក្នុងការគ្រប់គ្រងទឹកលូការបង្កើតក្របខណ្ឌស្ថាប័ននិងគតិយុត្តិនៃការគ្រប់គ្រងទឹកលូនៅPPCC គឺជាការចាំបាច់ដែលមិនអាចខ្វះបានក្នុងការចាប់ផ្តើមនិងអនុវត្តការគ្រប់គ្រងទឹកលូយ៉ាងពេញលេញប្រកបដោយនិរន្តភាពជាពិសេសការសាងសង់និងប្រតិបត្តិការនៃSTP ដូច្នេះការិយាល័យអភិវឌ្ឍប្រព័ន្ធលូនិងទឹកលូក្រោមប្រធាន ឬអភិបាលនៃ DPWT/PPCC ត្រូវបានស្នើឡើងក្នុង M/P ដែលមានគោលវិធីនៃ ចាប់ផ្តើមតូច និងលូតលាស់ធំ។ បន្ទាប់ពីបានបង្កើតការិយាល័យអភិវឌ្ឍន៏នេះ

ផែនការងនុវត្តតាមដំណាក់កាលសម្រាប់ការបង្កើតអង្គការអនុវត្តទឹកលូដែលឯកាជ្យពាក់ព័ន្ធនិនងការអភិវឌ្ឍធនធានមនុស្សត្រូវបានស្នើឡើង។ ស្របពេលនិងការបង្កើតក្របខណ្ឌស្ថាប័ននិងតាមផ្លូវច្បាប់នៃការគ្រប់គ្រងទឹកលូផែនការសាងសង់តាមដំណាក់កាលត្រូវបានបង្កើតឡើងដើម្បីបង្កើនបទពិសោធន៍និងចំណេះដឹងពីការគ្រប់គ្រងទឹកលូ។ យោងតានផែនការសាងសង់ដំណាក់កាលនេះ គម្រោងដើម មុនពេលមានដំណាក់កាលទាំងបីនៃការសាងសង់STP ត្រូវបានស្នើសម្រាប់តំបន់ប្រព្រឹត្តិកម្មជើងឯក។ គម្រោងដើមត្រូវបានកំណត់ឡើងក្នុងPre-F/S។ ការបង្កើតក្របខណ្ឌស្ថាប័ននិងតាមផ្លូវច្បាប់តាមដំណាក់កាលជាមួយនិងការអនុវត្តគម្រោងដើមឆ្លើយតបតាមការអនុវត្តដ៏រលូននិងប្រកបដោយនិរន្តភាពនៃគម្រោងទឹកលូបន្តបន្ទាប់នៅPPCC។

### ៣.១.២.ការគ្រប់គ្រងប្រព័ន្ធទឹកលូ

ចំពោះការគ្រប់គ្រងប្រព័ន្ធទឹកលូPPCC បានបែងចែកចេញជាតំបន់អាងរងទឹកភ្លៀងចំនួន២៥និងវិធានការសាងសង់ ដែលរួមមានប្រឡាយទឹកលូ ស្ថានីយបូមទឹក និងស្រះស្តុបទឹក ត្រូវបានស្នើឡើង ដោយគិតពីលក្ខខណ្ឌឋានលេខាសាស្ត្រដូចជាលទ្ធភាពនៃសំណង់ប្រឡាយដែលមានសម្រាប់ឆ្នាំគោលដៅ២០៣៥។ ក្របខណ្ឌស្ថាប័ននិងអនុវត្តការគ្រប់គ្រងប្រព័ន្ធទឹកលូត្រូវបានបង្កើតឡើងរួចរាល់ក្នុងកម្រិតមួយតាមរយៈការអនុវត្តគម្រោងកែលម្អប្រព័ន្ធលូដូចជា គម្រោងការពារពីទឹកជំនន់ និងគម្រោងកែលម្អប្រព័ន្ធលូក្នុងរាជធានីភ្នំពេញ។ ក៏ប៉ុន្តែការពង្រឹងក្របខណ្ឌស្ថាប័នត្រូវបានស្នើឡើងពីព្រោះក្របខ័ណ្ឌបច្ចុប្បន្នមានភាពមិនគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងប្រព័ន្ធលូជាច្រើនដែលបានស្នើឡើងក្នុងM/P ឲ្យបានរលូនដែលឆ្លើយតបទៅនិងនគរូបនីយកម្ម។

## ៣.២.ការបញ្ចេញកាកសំណល់រាវដោយមិនបានធ្វើប្រព្រឹត្តកម្មកម្ចាត់

រោចក្រមួយចំនួនជាពិសេសរោងចក្រវាយនភ័ណ្ឌ និងជ្រលក់ពណ៌ រោងចក្របោកគក់ ឬបោះពុម្ព និងរោងចក្រកែច្នៃផលិតផលកសិ-ឧស្សាហកម្មបានបញ្ចេញសំណល់រាវរបស់ខ្លួនដោយមិនបានធ្វើប្រព្រឹត្តកម្មសម្អាត ឬអាងប្រព្រឹត្តកម្មខ្លះមិនបានដំណើរការឲ្យជាប់លាប់ និងអាងប្រព្រឹត្តកម្មខ្លះទៀតមិនមានសមត្ថភាពឆ្លើយតបទៅនឹងបរិមាណសំណល់រាវដែលបានបង្កើតនិងបញ្ចេញ។ ដែលជាហេតុឲ្យមានការពុលដោយផ្ទាល់ ឬដោយប្រយោលទៅដល់គុណភាពទឹក ដី និងបង្កផលប៉ះពាល់ទៅដល់សុខភាពរបស់ប្រជាពលរដ្ឋដែលរស់នៅជុំវិញប្រភពបំពុល។ ក្រសួងបរិស្ថានបានដាក់ចេញនូវវិធានការចំពោះមុខមួយចំនួនដូចខាងក្រោម៖

- ចំពោះរោងចក្រ សហគ្រាស និងសប្បិកម្ម ដែលពុំទាន់មានអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវត្រូវតែរួសរាន់រៀបចំប្រព្រឹត្តកម្មសម្អាតសំណល់រាវឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសមុន និងបង្ហូរចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ឬប្រភពទឹកសាធារណៈដទៃទៀត
- ចំពោះរោងចក្រ សហគ្រាស និងសប្បិកម្ម ដែលមានអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ ប៉ុន្តែអាងប្រព្រឹត្តកម្មសម្អាតនោះមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ឬពុំមានលទ្ធភាពធ្វើការសម្អាតសំណល់រាវឲ្យឆ្លើយតបតាមកម្រិតកំណត់ស្តង់ដារ ត្រូវតែធ្វើការកែតម្រូវអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវជា

បន្ទាន់ ដោយធ្វើយ៉ាងណាដើម្បីធានាឲ្យការបញ្ចេញសំណល់រាវរបស់ខ្លួនមិនបង្កផលប៉ះពាល់ដល់បរិស្ថាន និងសុខភាពប្រជាពលរដ្ឋ

- ចំពោះរោងចក្រ សហគ្រាស និងសប្បិកម្ម ដែលមានអាងប្រព្រឹត្តកម្មសម្អាតត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសរួច ត្រូវតែដាក់ឲ្យដំណើរការជាប់ជាប្រចាំ ហើយសំណល់រាវដែលបានធ្វើប្រព្រឹត្តកម្មសម្អាតរួចត្រូវតែឆ្លើយតបតាមកម្រិតកំណត់ស្តង់ដារនៃការបញ្ចេញ
- សំណល់រាវដែលបានធ្វើប្រព្រឹត្តកម្មសម្អាតរួច ត្រូវបង្ហូរតាមបណ្តាញលូដាច់ដោយឡែក និងនៅត្រង់ចំណុចបញ្ចេញនៅខាងក្រៅបរិវេណរោងចក្រមុនតភ្ជាប់ទៅប្រព័ន្ធសាធារណៈ ឬបញ្ចេញទៅក្នុងប្រភពទឹក ប្រភពទឹកសាធារណៈ នៅត្រង់ចំណុចបញ្ចេញនេះត្រូវរៀបចំអណ្តូងលូ ដែលមានគម្របអាចបិទងសម្រាប់ធ្វើការវិភាគ
- ការបញ្ចេញសំណល់រាវក្រោយប្រព្រឹត្តកម្មសម្អាតរួច ចូលទៅក្នុងប្រព័ន្ធលូ ឬប្រភពទឹកសាធារណៈត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុន
- ម្ចាស់ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងឡាយណាដែលខកខាន មិនបានអនុវត្តតាមបណ្តាវិធានការដូចមានចែងក្នុងសេចក្តីជូនដំណឹងនេះ និងលិខិតបញ្ជាកែប្រែជាលាយលក្ខណ៍អក្សររបស់ក្រសួងបរិស្ថាន ម្ចាស់ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងនោះ នឹងត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងត្រូវប្រឈមចំពោះមុខច្បាប់ជាធរមាន ដោយអនុលោមតាមទំហំនៃបទល្មើសដែលខ្លួនបានប្រព្រឹត្តជាក់ស្តែង។

## ៣.៣.ការបំពុលនៃកាកសំណល់រាវ

### ៣.៣.១.ការបំពុលបរិស្ថាន

ការបំពុលបរិស្ថានគឺជាការបង្កភាពកខ្វក់ទៅលើសារធាតុ និងជីវចំរុះគ្រប់ប្រភេទលើផែនតាមរយៈការបញ្ចេញសារធាតុពុលគ្រប់ទម្រង់រួមមាន រឹង រាវ និងឧស្ម័ន។ ថាមពលដូចជាកម្តៅ សម្លេង ឬវិទ្យុសកម្ម ដែលបញ្ចេញទៅមជ្ឈដ្ឋានខាងក្រៅក៏អាចប៉ះពាល់ដល់បរិស្ថានបានដែរ។

ផលវិបាកនៃការបំពុលបរិស្ថាន វាជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សុខភាពមនុស្ស សុខភាពសត្វព្រៃនិងបន្លែ បរិស្ថានទូទៅ។ ការបំពុលមិនត្រឹមតែបង្កឲ្យមានពិការភាពរាងកាយប៉ុណ្ណោះទេថែមទាំងបង្កឲ្យមានបញ្ហាផ្លូវចិត្ត និងអាកប្បកិរិយាចំពោះមនុស្សផងដែរ។

ផលវិបាកចំបងទាំង ៨យ៉ាងនៃការបំពុលបរិស្ថាន៖

- បង្កើនលំអង
- ការកើនឡើងនៃជម្ងឺទឹក
- ការបាត់បង់ជីវចម្រុះ
- បញ្ហាសុខភាពចំពោះមនុស្ស

- ផលប៉ះពាល់អវិជ្ជមានទៅលើការលូតលាស់របស់រុក្ខជាតិ
- កម្តៅផែនដី
- ការថយចុះស្រទាប់អូហ្សូន
- ការវិចរិលបរិស្ថាន។

មានកត្តាច្រើនដែលនាំឲ្យមានការបំពុលដល់បរិស្ថាន។ ដោយកត្តាទាំងនោះរួមមានៈ

1. *ការបំពុលដោយឧស្សាហកម្ម* : ដោយសារតែឧស្សាហកម្មជាកន្លែង ដែលបញ្ចេញថាមពលច្រើន និងមានផ្ទុកសារធាតុគីមី ការបំពុលដោយសំណល់ អាចបង្កគ្រោះថ្នាក់ដល់សតិបញ្ញារបស់កុមារ និងធ្វើឲ្យការលូតលាស់យឺតជាងធម្មតា។ ឧស្សាហកម្ម ដែលបំពុលច្រើនជាងគេគឺឧស្សាហកម្មផលិតក្រដាស និងចំណីអាហារ។
2. *ការបំពុលដោយកសិកម្ម* : ដើម្បីធ្វើស្រែចម្ការ ដាំដំណាំ បន្លែផ្លែឈើ ឲ្យទទួលបានផ្លែផ្កាល្អ កសិករត្រូវការប្រើប្រាស់ថ្នាំគីមី សម្លាប់សត្វល្អិតចង្រៃ ដូចជាដង្កូវ និងសត្វល្អិតជាដើម។ ការប្រើជីនិង ថ្នាំសម្លាប់សត្វល្អិត ជាកត្តាដែលបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរ។ កសិដ្ឋានចិញ្ចឹមសត្វជ្រូក បង្កើតឲ្យមានលាមក និងទឹកនោម ដែលបញ្ចេញនូវឧស្ម័នពុលទៅក្នុងខ្យល់ ហើយជ្រាបចូលទៅក្នុងដី បំពុលទឹកផងដែរ។
3. *ការបំពុលដោយវិទ្យុសកម្ម* : រោងចក្រនុយក្លេអ៊ែរដែលមានផ្ទុយសារធាតុអ៊ុយរ៉ាញ៉ូម ដើម្បីផលិតគ្រឿងអគ្គិសនីដែលពួកយោធាប្រើនៅក្នុងនាវាមុជទឹក និងផលិតគ្រាប់បែក ដោយបន្សល់សំណល់ និងបញ្ចេញនូវកម្មរស្មីថាមពល ជាហេតុនាំឲ្យបង្កគ្រោះថ្នាក់ដល់សុខភាព បណ្តាលឲ្យស្លាប់ មានជម្ងឺមហារីក ធ្វើឲ្យគ្មានកូន ឬធ្វើឲ្យទារកមានកាយសម្បទាមិនគ្រប់គ្រាន់ជាដើម។
4. *ការបំពុលដោយសំណល់ផ្សេងៗ* : ការបោះចោលសំណល់ដូចជា ថង់ប្លាស្ទិក កាតុង ក្រដាស កែវសំណល់សរីរាង្គ សំបកដប សំបកកង់ឡាន សំបកកង់ម៉ូតូ វត្ថុទាំងអស់នេះ មិនងាយរលាយនៅក្នុងធម្មជាតិទេ ទោះជារលាយក៏មានរយៈពេលយូរដែរ ធ្វើឲ្យបរិស្ថានមិនស្រស់ស្រាយ។ មិនតែប៉ុណ្ណោះ ការបោះចោលសំរាមពាសវាលពាសកាល នាំឲ្យស្ទះលូ និងត្រីងាប់ផងដែរ។

### ៣.៣.២.បំពុលទឹក

ការបំពុលទឹកកើតឡើងនៅពេលដែលទឹករងការប៉ះពាល់ដោយសារបរិមាណសារធាតុពុលដ៏សន្ធឹកសន្ធាប់ នៅពេលដែលទឹកមិនសមស្របសម្រាប់ការប្រើប្រាស់ មានន័យថាវាត្រូវបានបំពុលហើយ។ ការបំពុលទឹក អាចត្រូវបានគេឲ្យនិយមន័យច្រើនយ៉ាងផ្សេងៗពីគ្នា។ ជាទូទៅ ករបំពុលទឹកគឺជាការធ្វើឲ្យកង្វក់ដល់ទឹកនៅពេលដែលសារធាតុបំពុកនានា បានហូរចូលទៅក្នុងប្រភពទឹកដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម (ការដកយកសារធាតុបំពុលចេញ)។ ការបំពុលទឹកភាគច្រើន គឺបណ្តាលមកពីសំណល់ពីរោងចក្រឧស្សាហកម្ម កសិកម្ម និងតាមផ្ទះ ដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្ស និងសត្វ ក៏ដូចជាគុណភាពបរិស្ថាននៃប្រភពទឹកទាំងមូល។



នៅប្រទេសកម្ពុជា លទ្ធភាពទទួលបានទឹកស្អាត និងមានសុវត្ថិភាព នៅតែជាបញ្ហាប្រឈមនៅឡើយ ជាពិសេសសម្រាប់គ្រួសារនៅតាមទីជនបទ ពីព្រោះការផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធទឹកនានា នៅមានកម្រិតនៅឡើយ សម្រាប់តំបន់នៅក្រៅពីទីក្រុងធំៗ។

ការបំពុលទឹក មានប្រភពបំពុលផ្ទាល់ និងមិនផ្ទាល់ ចំពោះប្រភពបំពុលផ្ទាល់ គឺកើតឡើងពេលសារធាតុគ្រោះថ្នាក់ផ្សេងៗត្រូវបានបង្ហូរដោយផ្ទាល់ទៅក្នុងទឹកតាមរយៈ បំពង់ ឬលូ ។ ចំណែកឯប្រភពមិនផ្ទាល់វិញ គឺជាការបំពុលទឹកដោយប្រយោលតាមការនាំយកសារធាតុបំពុលផ្សេងៗតាម។

**៣.៣.៣.បំពុលដី**

ការបំពុលដីបណ្តាលមកពី បញ្ហាជាច្រើនដែលកើតចេញពីសកម្មភាពរបស់មនុស្ស។ សកម្មភាពរុករករ៉ែ និងប្រេងដែលបណ្តាលឲ្យមានការចុះខ្សោយនៃរូបវន្តនិងគីមីនៃដី។ ម្យ៉ាងវិញទៀតសកម្មភាពកសិកម្មក៏ធ្វើឲ្យដីខូចផងដែរតាមរយៈការប្រើប្រាស់គ្រឿងកសិកម្មនិងគ្រឿងម៉ាស៊ីនកសិកម្មច្រើនពេក។ ជីគីមី និងថ្នាំសម្លាប់សត្វល្អិតជះឥទ្ធិពលដល់ចំនួនប្រជាជននៃមីក្រូសាស្ត្រនៅក្នុងដីក៏ដូចជារុក្ខជាតិ។



# សេចក្តីសន្និដ្ឋាន

ជារួម ការគ្រប់គ្រងសំរាមនៅប្រទេសកម្ពុជា និងប្រទេសដទៃទៀត ដែលជាសមាជិកសហគមន៍អាស៊ាន និងប្រទេសអភិវឌ្ឍន៍មានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ប្រទេសកម្ពុជា ថៃ និងវៀតណាម មានទំនោរប្រើប្រាស់វិធីសាស្រ្តគ្រប់គ្រងសំរាមតាមបែបសាមញ្ញ ដែលមានឧបករណ៍បច្ចេកវិទ្យាកម្រិតទាប។ ចំពោះប្រទេសសិង្ហបុរី ប្រើប្រាស់បច្ចេវិទ្យាទំនើបជាងគេ សម្រាប់គ្រប់គ្រងសំរាម (រោងចក្របម្លែងសំរាមទៅជាថាមពល) ព្រមទាំងមានច្បាប់ពាក់ព័ន្ធនឹងសំរាម និងពង្រឹងការអនុវត្តន៍ច្បាប់ល្អពីស្ថាប័នរដ្ឋាភិបាល។ ប្រទេសអាល្លឺម៉ង់ និងចក្រភពអង់គ្លេសប្រើប្រាស់ឧបករណ៍ទំនើបប្រកបដោយបច្ចេកទេសខ្ពស់ សម្រាប់ការគ្រប់គ្រងសំរាម(រោងចក្របម្លែងសំរាមទៅជាថាមពល និងការបំបែកសារធាតុតាមអែនអេរ៉ូប៊ិក នៅចក្រភពអង់គ្លេស)។

ពាក់ព័ន្ធនឹង ផលប៉ះពាល់នៃការគ្រប់គ្រងសំរាមនៅកម្ពុជា បើទោះបីជាមិនមានការសិក្សាស្រាវជ្រាវជាក់លាក់ណាមួយ ទៅលើផលប៉ះពាល់នៃការចោលសំរាមនៅទៅសាធារណៈ ការដុតសំរាម និងការចោលសំសំណល់នៅទីលានចាក់សំរាមក៏ដោយ ក៏ជាទូទៅគេសង្កេតឃើញថា ការអនុវត្តន៍នៃការគ្រប់គ្រងសំរាម ឬសំណល់បែបនេះ ទំនងជាមានផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសុខភាពមនុស្ស។ នៅក្នុងប្រទេសថៃ និងវៀតណាមការចោលសំណល់នៅទីលានចាក់សំរាម ក៏បណ្តាលឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសុខភាពមនុស្ស។ ប៉ុន្តែការចោលសំណល់នៅទីលានចាក់សំរាមនៅក្នុងប្រទេសសិង្ហបុរី មិនមានផលប៉ះពាល់នោះទេ ពីព្រោះ ទីលានចាក់សំរាមនៅក្នុងប្រទេសសិង្ហបុរី ត្រូវបានកសាង និងរចនាឡើងដែលមានបច្ចេកទេស ដើម្បីបង្ការនូវផលប៉ះពាល់ជាអវិជ្ជមានរបស់ទីលានចាក់សំរាម។

ប្រទេសកម្ពុជា អាចពិនិត្យមើលបទពិសោធន៍នានាដែលមានក្នុងប្រទេសទាំងនេះ ហើយយកមកអនុវត្តនូវបច្ចេកវិទ្យា និងកម្មវិធីផ្សេងៗ ដែលមានលក្ខណៈសមស្របបំផុត ហើយអាចយកមកអនុវត្តឲ្យស្របទៅនឹងបរិបទប្រទេសកម្ពុជា។ ឧទាហរណ៍ កម្មវិធីផ្សព្វផ្សាយ អប់រំនានា សម្រាប់យុវជន និងប្រជាពលរដ្ឋ ទូទៅពាក់ព័ន្ធនឹងបញ្ហាគ្រប់គ្រងសំរាម ឬសំណល់ អាចជាសកម្មភាពមួយក្នុងការអនុវត្តន៍កម្មវិធីគ្រប់គ្រងសំរាមឲ្យបានល្អសម្រាប់ប្រទេសកម្ពុជា។ លើសពីនេះទៀត ប្រទេសកម្ពុជាក៏អាចរៀនសូត្រពីប្រទេសសិង្ហបុរីផងដែរ ចំពោះរបៀបនៃការកសាង និងរចនានូវ ទីលានចាក់សំរាមដែលមានលក្ខណៈអនាម័យ។ ការដែលធ្វើដូចនេះ ផលប៉ះពាល់អវិជ្ជមានដែលពាក់ព័ន្ធនឹង ការចោលសំណល់នៅទីលានចាក់សំរាមនានា ទៅលើបរិស្ថាន និងសុខភាពមនុស្សនឹងត្រូវកាត់បន្ថយ។

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបទបង្ហាញស្តីពីការគ្រប់គ្រងសំរាមនិងកាកសំណល់រឹងនិងរាវនៅក្នុងរាជធានីភ្នំពេញ ខ្ញុំទាំងពីរនាក់ ពិតជាមានសេចក្តីរីករាយ រំភើប ដោយបានសិក្សាស្វែងយល់នូវចំណុចនីមួយៗនៃប្រធានបទខាងលើ ហើយពួកខ្ញុំបានសង្កេតឃើញថា ការគ្រប់គ្រងសំរាមនិងកាកសំណល់នៅក្នុងរាជធានីភ្នំពេញនូវមានលក្ខណៈមិនទាន់បានល្អប្រសើរនៅឡើយទេដោយពេលខ្លះយើងសង្កេតឃើញថានៅមានការប្រមូលមិនទាន់ពេលវេលានិងមានការធ្វើឲ្យមានសំរាមនៅតាមទីសាធារណៈជាពិសេសទៀតនោះគឺថាមានក្លិនមិនល្អដែលអាចធ្វើឲ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋដែលរស់នៅជិតតំបន់នោះផងដែរ មិនត្រឹមតែការប្រមូលសំរាមរបស់ក្រុមហ៊ុនមិនបានទាន់ពេលវេលានោះទេកត្តាមួយចំនួនទៀតក៏បណ្តាលមកពីការដែលប្រជាពលរដ្ឋដាក់សំរាមរបស់ខ្លួនមិនបានត្រឹមត្រូវផងដែរ ដែលជាហេតុបណ្តាលឲ្យទីក្រុងរបស់យើងមានសំរាមនិងសោភណ្ឌភាពទីក្រុងមិនទាន់មានភាពល្អឥតខ្ចោះនៅឡើយ។

ខ្ញុំទាំងពីរនាក់មាននូវគំនិតដ៏តូចមួយ ក្នុងការចូលរួមចំណែកដើម្បីការការពារការគ្រប់គ្រងសំរាមនិងកាកសំណល់នៅក្នុងរាជធានីភ្នំពេញគឺៈ

*១.ចំពោះរាជរដ្ឋាភិបាល សាលារាជធានីភ្នំពេញនិងស្ថាប័នមានសមត្ថកិច្ចទាក់ទងពីការគ្រប់គ្រងសំរាម*

- ត្រូវធ្វើការយកចិត្តទុកដាក់ទៅលើបញ្ហានៃការគ្រប់គ្រងសំរាមនេះឲ្យទទួលបានទាំងប្រសិទ្ធិភាពនិងប្រសិទ្ធិផល
- ត្រូវមានការរៀបចំផែនការក្នុងការចុះត្រួតពិនិត្យនៅតាមបណ្តាទីសាធារណៈដូចជាផ្សារឬក៏កន្លែងសាធារណៈផ្សេងៗទៀតអំពីបញ្ហានៃការទុកដាក់សំរាមរបស់ពួកគេមុនមានអ្នកប្រមូលធ្វើការប្រមូល
- ត្រូវមានការរៀបចំសកម្មភាពក្នុងការចុះអប់រំផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីបញ្ហាសំរាមនិងគុណវិបត្តិរបស់វាដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់យើងជាពិសេសគឺអ្នកដែលរស់នៅជិតកន្លែងចាក់សំរាម
- ហើយអ្វីដែលជាចំណុចសំខាន់មួយវិញទៀតគឺស្ថាប័នមានសមត្ថកិច្ចត្រូវមានការសហការគ្នាជាមួយក្រុមហ៊ុនឯកជនដែលធ្វើការប្រមូលសំរាមនេះឲ្យបានច្រើនក៏ល្អដើម្បីកុំឲ្យមានបញ្ហាប្រឈមទាក់ទងនិងការប្រមូលសំរាមមិនទាន់ពេលវេលាជាដើម
- ស្ថាប័នមានសមត្ថកិច្ចត្រូវមានការរៀបចំនិងបង្កើតទីតាំងចាក់សំរាមបន្ថែមពីលើទីតាំងដែលប្រើប្រាស់ក្នុងពេលបច្ចុប្បន្នឲ្យបានកាន់តែច្រើនកាន់តែល្អ

*២.ចំពោះប្រជាពលរដ្ឋ*

- ត្រូវស្តាប់តាមការណែនាំរបស់ស្ថាប័នមានសមត្ថកិច្ចឲ្យបានត្រឹមត្រូវ
- ត្រូវចេះរៀបចំទុកដាក់សំរាមរបស់ខ្លួនដែលបានប្រើប្រាស់រួចហើយឲ្យបានត្រឹមត្រូវនិងមិនត្រូវយកសំរាមមកបោះចោលពោសវាលពោសកាលនោះទេ

- ត្រូវយកសំរាមមកដាក់ចោលឲ្យទាន់ពេលវេលាដែលក្រុមហ៊ុនប្រមូលសំរាមបានមកប្រមូល
- ត្រូវមានតួនាទីក្នុងការចូលរួមសម្អាតបរិស្ថានក៏ដូចជាធ្វើការណែនាំដល់ក្មេងៗជំនាន់ក្រោយឲ្យយល់ដឹងអំពីផលប៉ះពាល់របស់សំរាម
- និងមួយវិញទៀតដើម្បីធ្វើជាពលរដ្ឋល្អគឺយើងត្រូវចូលរួមថែរក្សាបរិស្ថានឲ្យបានល្អនិងគ្រប់គ្រង់សំរាមឲ្យបានល្អ ដូច្នេះហើយដើម្បីធ្វើឲ្យទីក្រុងស្អាតនិងគ្មានសំរាមគឺផ្តើមចេញមកពីយើងទាំងអស់គ្នា។

ស្របតាមគំនិតដ៏ស្តួចស្តើងខាងលើនេះខ្ញុំទាំងពីរនាក់សង្ឃឹមថា និងបានជាជ្រុងមួយនៃគំនិតក្នុងការរួមចំណែកការគ្រប់គ្រងសំរាមនៅក្នុងរាជធានីភ្នំពេញក៏ដូចជាការការពារសោភណ្ឌភាពរបស់ទីក្រុងយើងឲ្យបានស្អាតផងដែរ និងអាចជាគំនិតក្នុងការដាស់តឿនស្មារតីអ្នកជំនាន់ក្រោយឲ្យយល់ដឹងកាន់តែច្បាស់អំពីបញ្ហាសំរាមនិងចូលរួមទាំងអស់គ្នាក្នុងការការពារបរិស្ថានរបស់រាជធានីយើងឲ្យមានភាពកាន់តែស្រស់ស្អាតបន្តទៀត។

# ឯកសារយោង


1. អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង(១៩៩៨)
2. អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
3. គោលនយោបាយគ្រប់គ្រងសំរាមទីក្រុង
4. ច្បាប់និងលិខិតបទដ្ឋាន- ក្រសួងបរិស្ថាន
5. ការសិក្សាអំពីគម្រោងកែលំអរប្រព័ន្ធលូ និងទឹកសម្អុយនៅរាជធានីភ្នំពេញ
6. https://www.rfi.fr/km/cambodia/20191127 នាទីសុខភាពនិងអនាម័យ
7. https://www.moe.gov.kh រួមគ្នាកាត់បន្ថយប្លាស្ទិក
8. https://thmeythmey.com
9. https://www.pic.org.kh បញ្ហាប្រឈមនៃការគ្រប់គ្រងសំរាមនៅកម្ពុជា និងបទពិសោធន៍នៃការគ្រប់គ្រងសំរាមនៅប្រទេសផ្សេងៗ (ខែឧសភា ឆ្នាំ២០១៥)

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១

- ❖ ការដុតបំលែងសំរាមទៅជាថាមពលនៅក្នុងប្រទេសសិង្ហបុរី

ទីភ្នាក់ងារបរិស្ថានជាតិរបស់ប្រទេសសិង្ហបុរី យកវិធីសាស្ត្រដុតសំរាមទោជាថាមពល មកប្រើប្រាស់ ដោយសារតែមានការបារម្ភពាក់ព័ន្ធនឹង ផ្ទៃដីមានទំហំតូចចង្អៀតព្រមទាំងទីលានចាក់សំរាមនឹងមិនអាចទ្រទ្រង់សំរាម ឬសំណល់រឹងដែលបង្កើតឡើងនៅក្នុងប្រទេសបាន។ រោងចក្រដែលបំលែងសំរាមទៅជាថាមពលបានចាប់ដំណើរការដំបូងក្នុងឆ្នាំ ១៩៧៩។ ដំណើរការនៃការបំលែងសំរាមទៅជាថាមពល មានដំណាក់កាលដូចជា៖

- សំរាមត្រូវដឹងបញ្ជូនទៅដាក់ក្នុងកន្លែងផ្ទុកនឹងសំណល់មុននឹងដុតផ្តើម
- ឧបករណ៍បំបែកសំរាមដែលអាចបង្វិកបានត្រូវបាន ប្រើដើម្បីបំបែកសំរាមដែលផ្តុំគ្នា ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការដុតសំរាមទាំងនោះ
- បន្ទាប់មកសំរាមដែលមាននៅក្នុងកន្លែងផ្ទុកសំរាម ត្រូវយកទៅដាក់ក្នុងឡដុតសំរាម សម្រាប់ដុត
- កម្តៅដែលភាយចេញមកពីដំណើរការនៃការដុតសំរាម ត្រូវយកទៅប្រើដើម្បីបង្កើតចំហាយដ៏សែនក្តៅនៅក្នុងធុងទឹកក្តៅ
- បន្ទាប់មក គេយកចំហាយទាំងនេះ ទៅប្រើដើម្បីជំរុញម៉ាស៊ីនធីបូ ឲ្យបង្កើតថាមពលអគ្គិសនី។

បច្ចុប្បន្នប្រទេសសិង្ហបុរី មានរោងចក្របំលែងសំរាមទៅជាថាមពលអគ្គិសនីចំនួន ៤ ដែល ៤៧.៦% នៃសំរាមសរុបត្រូវបានយកបោះចោល និងដុតនៅរោងចក្រទាំងនេះ។

## 2020 Waste Statistics and Overall Recycling

| Waste Type | Total Generated ('000 tonnes) | Total Recycled ('000 tonnes) | Recycling Rate | Total Disposed ('000 tonnes) |
|---|---|---|---|---|
| Paper/Cardboard | 1,144 | 432 | 38% | 712 |
| Ferrous metal | 934 | 930 | 99% | 4 |

| | | | | |
|---|---|---|---|---|
| Plastics | 868 | 36 | 4% | 832 |
| Construction & Demolition | 825 | 822 | 99% | 3 |
| Food | 665 | 126 | 19% | 539 |
| Horticultural | 313 | 249 | 80% | 64 |
| Wood | 304 | 195 | 64% | 109 |
| Ash & sludge | 228 | 16 | 7% | 211 |
| Textile/Leather | 137 | 6 | 4% | 131 |
| Used slag | 106 | 104 | 99% | 2 |
| Non-ferrous metal | 75 | 73 | 98% | 2 |
| Glass | 66 | 7 | 11% | 58 |
| Scrap tyres | 23 | 22 | 95% | 1 |
| Others (stones, ceramics, etc.) | 193 | 21 | 11% | 173 |
| **Overall** | **5,880** | **3,040** | **52%** | **2,841** |

ឧបសម្ព័ន្ធទី២ ៖ រូបភាពស្តីពី ឋានុក្រមសំរាម



# អនុក្រឹត្យស្តីពី

# ការគ្រប់គ្រង សំរាមសំណល់រឹង នៅទីប្រជុំជន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១១៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## សម្រេច
## ជំពូកទី១
## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅៈ

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យជាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីជានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្តោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្តោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្តាលមកពីភាពអសកម្មនៃអ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់កកពីអាងស៊ិបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្តល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នាក្នុងការផ្តល់សេវារួមជាមួយគ្នា។

គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។

ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្ត៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទីថ្ម និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្តៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬជឹងកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្តរបស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាត យកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្តឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្តឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យ និងកែសម្រួលនូវកិច្ចសន្យាផ្តល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

## ឧបសម្ព័ន្ធទី១
## សន្ទានុក្រម

១- **សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

២- **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាពអាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៣- **សំណល់រឹងឧស្សាហកម្ម** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាពផលិតកម្មនៃរោងចក្រ ឬសហគ្រាសដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

៤- **សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹង រាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចំលងជំងឺ ឬធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្កឱ្យមានជំងឺមហារីក ឬសារធាតុគីមីពុលដទៃទៀត ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាចមានប្រភពមកពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មរ៉ែ។

៥- **ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងធ្វើជាជីកំប៉ុស្តិ៍ កែច្នៃ ទាញយកថាមពល ឬសារប្រយោជន៍នានា។

៦- **ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

៧- **ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។

៨- **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើតសម្រាប់គោលបំណងការទាញយកធនធាន ឬដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។

៩- **ទីលាន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

១០-**ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

ក). ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន ដូចជា ការដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដុតនៅក្នុងឡ។

ខ). ការដកយក ឬកម្ទេចចោលជាតិពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជម្ងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន។

១១- **ទីប្រជុំជន** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅដ្ឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

១២- **ទីតាំង** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម។

១៣- **អាងស្តុបទិក** សំដៅដល់អាងស្តុកសំណល់បង្គន់អនាម័យបឋម។

១៤- **ពិន័យអន្តរការណ៍** សំដៅដល់ការតម្រូវជនប្រព្រឹត្តល្មើសទៅនឹងប្បញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះ បង់ប្រាក់ពិន័យតាមកម្រិតទណ្ឌកម្មដែលបានប្រព្រឹត្តល្មើស។

១៥- **សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

## ឧបសម្ព័ន្ធទី២

## សំណល់គ្រោះថ្នាក់ ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍

សំណល់គ្រោះថ្នាក់ដែលបង្កើតឡើងនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍រួមមាន៖

១- សំណល់អាគុយ និងថ្មពិល ឬថ្មសាកគ្រប់ប្រភេទ។

២- សំណល់គ្រឿងបរិក្ខារអគ្គីសនី និងអេឡិចត្រូនិក។

៣- សំណល់សំបកដប ឬកំប៉ុងដែលមានប្រឡាក់សារធាតុគីមី ឬថ្នាំពុលកសិកម្ម។

៤- សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ។

៥- សំណល់ប្រេងម៉ាស៊ីន។

៦- សំណល់ថ្នាំលាបថ្នាំជ្រលក់ពណ៌ និងសម្ភារវេចខ្ចប់។

៧- សំណល់ទឹកខ្មៅបោះពុម្ព។

៨- សំណល់ដែលជាសមាសធាតុអាបេស្តូស។